# អំពើហិង្សា លើស្ត្រី

## នៅកម្ពុជាឆ្នាំ២០០៦

*នាងខ្ញុំឈ្មោះ ស្រី មុំ អាយុ ៤២ ឆ្នាំ។ ប្តីនាងខ្ញុំ បានវាយធ្វើបាបជាប្រចាំ។*
*នេះគឺ រឿងរបស់ខ្ញុំ។*

របាយការណ៍ លីកាដូ

ខែមិនា ឆ្នាំ ២០០៧

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

## សម្ព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា នឹងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និង ស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ នឹងឃ្លាំមើលរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង ១២ ខេត្ត-ក្រុងផ្សេងទៀត។

**លីកាដូ កំពុងបន្តសកម្មភាពរបស់ខ្លួនតាមរយៈការិយាល័យកម្មវិធីទាំង ៧ របស់ខ្លួន ដូចខាងក្រោមៈ**

- **ការិយាល័យឯកសារ និងធនធានព័ត៌មាន** គឺជាការិយាល័យដែលរក្សាចងក្រងសំណុំរឿងទៅក្នុងទិន្នន័យដើម្បីងាយស្រួលក្នុងការរកឯកសារនឹងវិភាគឱ្យបានឆាប់រហ័ស។
- **ការិយាល័យអប់រំសិទ្ធិមនុស្ស** គឺជាការិយាល័យដែលបើកវគ្គបណ្តុះបណ្តាលសិទ្ធិមនុស្សដល់ក្រុមគោលដៅនានាដូចជា មន្ត្រីរាជការ សិស្ស និស្សិត ព្រះសង្ឃ ព្រមទាំងបើកវគ្គផ្សព្វផ្សាយសិទ្ធិមនុស្សដល់សាធារណៈជននានាថែមទៀតផង។
- **ការិយាល័យស៊ើបអង្កេត** គឺជាការិយាល័យដែលមានតួនាទីជាអ្នកស៊ើបអង្កេតករណីរំលោភសិទ្ធិមនុស្ស នឹងជួយជនរងគ្រោះនានាក្នុងដំណើរការបណ្តឹងដែលពាក់ព័ន្ធខាងផ្នែកច្បាប់។ បុគ្គលិក ដែលមានការហ្វឹកហ្វឺនជំនាញត្រឹមត្រូវក៏បានឃ្លាំមើលពន្ធនាគារចំនួន ១៨ ដើម្បីវាយតម្លៃស្ថានភាពពន្ធនាគារ ព្រមទាំងជួយឱ្យពិរុទ្ធជនទាំងឡាយទទួលបាននូវតំណាងផ្នែកច្បាប់ទៀតផង។
- **ការិយាល័យពេទ្យ** គឺជាការិយាល័យដែលផ្តល់សេវាវេជ្ជសាស្ត្រដល់ពិរុទ្ធជន ទណ្ឌិត និង មន្ត្រីពន្ធនាគារនៅតាមពន្ធនាគារចំនួន ១៨ កន្លែង។ ក្រៅពីនេះ ក៏បានផ្តល់សេវាវេជ្ជសាស្ត្រនឹងជួយបញ្ជូនជនរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្សទៅមន្ទីរពេទ្យផងដែរ។
- **កម្មវិធីប្រឆាំងនឹងទារុណកម្ម** ជាការិយាល័យផ្តល់សេវាកម្មស្តារលទ្ធភាពទូទៅដល់ជនរងគ្រោះដោយអំពើទារុណកម្ម នឹងធ្វើការតស៊ូមតិប្រឆាំងនឹងអំពើទារុណកម្ម។
- **ការិយាល័យសិទ្ធិកុមារ** ជាការិយាល័យដែលផ្តល់ការអប់រំសិទ្ធិកុមារដល់សាធារណៈជនទូទៅ ស្ថាបនាបណ្តាញការពារកុមារនៅតាមមូលដ្ឋាននានា នឹងស៊ើបអង្កេតការរំលោភសិទ្ធិកុមារ ។
- **ការិយាល័យសិទ្ធិស្ត្រី** ជាការិយាល័យអប់រំសិទ្ធិស្ត្រីដល់សាធារណៈជនទូទៅ ស៊ើបអង្កេតការរំលោភសិទ្ធិស្ត្រី នឹងធ្វើការតស៊ូមតិ ដើម្បីឱ្យមានការផ្លាស់ប្តូរផ្នែកច្បាប់ និង សង្គម។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទង:**

លោកស្រី វេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការលីកាដូ

អាសយដ្ឋាន: អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្ស)

ផ្ទះលេខ ១៦, ផ្លូវលេខ ៩៩, រាជធានីភ្នំពេញ, កម្ពុជា

ទូរស័ព្ទ: (៨៥៥) ២៣ ៣៦០ ៩៦៥ / ៣៦៤៩០១

ទូរសារ: (៨៥៥) ២៣ ៣៦០ ៩៦៥ / ២១៧ ៦២៦

អ៊ីម៉ែល: contact@licadho.org

គេហទំព័រ: http://www.licadho.org/

# មាតិការឿង


**របាយការណ៍សង្ខេប** ~~~~~~~~~~~~~~~~~~~~~~~~ I

**១. បុព្វកថា** ~~~~~~~~~~~~~~~~~~~~~~~~ ១

**២. អំពើហិង្សាក្នុងគ្រួសារ** ~~~~~~~~~~~~~~~~~~~~~~~~ ៣

បញ្ហាអំពើហិង្សាក្នុងគ្រួសារ : រឿងរ៉ាវរបស់ស្រី មុំ ------------------------ ៧

ករណីអំពើហិង្សាក្នុងគ្រួសារដែលបានរាយការណ៍ ------------------------ ១១

ការឆ្លើយតបរបស់រាជរដ្ឋាភិបាលចំពោះអំពើហិង្សាក្នុងគ្រសារ ------------------------ ១២

**៣. អំពើរំលោភសេពសន្ថវៈ** ~~~~~~~~~~~~~~~~~~~~~~~~ ១៤

ករណីសិក្សា ២ : រំលោភសេពសន្ថវៈ ------------------------ ១៤

បញ្ហារំលោភសេពសន្ថវៈ : រឿងរ៉ាវរបស់ លី វីដែន ------------------------ ១៦

ករណីរំលោភសេពសន្ថវៈដែលបានរាយការណ៍ ------------------------ ២០

ករណីសិក្សា ៣ : ការរំលោភសេពសន្ថវៈជាពួក ------------------------ ២២

បញ្ហារំលោភសេពសន្ថវៈជាពួក : រឿងរបស់ដេត ------------------------ ២៥

ករណីរំលោភជាពួកដែលបានរាយការណ៍ ------------------------ ២៧

ការឆ្លើយតបរបស់រាជរដ្ឋាភិបាលចំពោះអំពើរំលោភសេពសន្ថវៈ ------------------------ ២៨

**៤. អំពើជួញដូរមនុស្សក្នុងគោលបំណងអាជីវកម្មផ្លូវភេទ** ~~~~~~~~~~~~~~~~ ៣០

បញ្ហាអំពើជួញដូរមនុស្ស: រឿងរ៉ាវរបស់ហោង ណារី ------------------------ ៣២

ករណីជួញដូរមនុស្ស ដើម្បីគោលបំណងអាជីវកម្មផ្លូវភេទដែលបានរាយការណ៍ ------------ ៣៦

ការឆ្លើយតបរបស់រាជរដ្ឋាភិបាលចំពោះអំពើជួញដូរមនុស្សដើម្បីគោលបំណងអាជីវកម្មផ្លូវភេទ ៣៨

**៥. សេចក្តីសន្និដ្ឋាន និង អនុសាសន៍** ~~~~~~~~~~~~~~~~~~~~~~~~ ៤១

# របាយការណ៍សង្ខេប

តាមប្រវត្តិសាស្ត្រពីអតីតកាល ប្រជាពលរដ្ឋកម្ពុជាបានទទួលរងនូវវប្បធម៌ហិង្សាមួយដែលប្រព្រឹត្តដោយរបបខ្មែរក្រហម និង ក្រុមនយោបាយផ្សេងៗទៀត។ ផលប៉ះពាល់នៃអំពើហិង្សានេះនៅតែបន្តមានឥទ្ធិពលមកលើប្រជាពលរដ្ឋជាច្រើននៅកម្ពុជា។ ក្រុមមួយដែលងាយរងគ្រោះជាងគេបំផុត គឺក្រុមស្ត្រីនៅកម្ពុជា។ អំពើហិង្សាលើស្ត្រីនៅកម្ពុជា - ជាពិសេសអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ និង អំពើជួញដូរមនុស្សក្នុងគោលបំណងធ្វើអាជីវកម្មផ្លូវភេទ - ទាំងនេះគឺជាបញ្ហារំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរជាទីបំផុត។

ទោះបីជាកម្ពុជាកំពុងចាប់ផ្តើមទទួលស្គាល់នូវភាពធ្ងន់ធ្ងរនៃអំពើហិង្សាមកលើស្ត្រីក៏ដោយ ក៏ទំហំនៃឆន្ទៈរបស់រាជរដ្ឋាភិបាលក្នុងការអប់រំតុលាការ នគរបាល និង សាធារណជននានាអំពីបញ្ហានេះ ព្រមទាំងការអនុវត្តន៍ច្បាប់ និង គោលនយោបាយនានាដែលជាការទប់ស្កាត់នូវសកម្មភាពល្មើសនេះ ក៏ដូចជាកិច្ចការពារជនរងគ្រោះនៅមានកំរិតទាបនៅឡើយ។

ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការលប់បំបាត់នូវរាល់ទម្រង់រើសអើងប្រឆាំងនារីភេទ (CEDAW) នៅឆ្នាំ១៩៩២ ហើយបានប្តេជ្ញាអនុវត្តគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជានៅឆ្នាំ ២០០០ កន្លងទៅ។ ឧបករណ៍ទាំងពីរនេះសុទ្ធតែបានចែងនូវមាត្រាមួយចំនួនស្តីពីការកាត់បន្ថយ និង លប់បំបាត់នូវអំពើហិង្សាលើស្ត្រី ប៉ុន្តែកន្លងមក រាជរដ្ឋាភិបាលនៅមិនទាន់បានចាត់វិធានការឱ្យបានគ្រប់គ្រាន់ ដើម្បីអនុវត្តឧបករណ៍ទាំងនេះនៅឡើយទេ។ ចាប់តាំងពីឆ្នាំ១៩៩២ គេបានពិនិត្យឃើញថា ការរីកចម្រើនរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយ និង លុបបំបាត់អំពើហិង្សាលើស្ត្រីនៅមានល្បឿនយឺតនៅឡើយ ហើយថែមទាំងមិនទាន់សមល្មមទៀតផង។ កាលពីឆ្នាំ២០០៦កន្លងទៅនេះ ក្នុងអំឡុងរយៈពេលដែលគ្របដណ្តប់ដោយរបាយការណ៍នេះ ពុំមានច្បាប់ថ្មី ឬគោលនយោបាយដែលមានឥទ្ធិពលណាមួយ ការពារស្ត្រីពីសំណាក់អំពើហិង្សា ត្រូវបានអនុម័ត ឬ អនុវត្តដោយរាជរដ្ឋាភិបាលឡើយ។

## អំពើហិង្សាក្នុងគ្រួសារ

ទន្ទឹមនឹងការអនុម័តច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះដោយអំពើហិង្សាកាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៥ កន្លងទៅ រាជរដ្ឋាភិបាលបានទទួលស្គាល់នូវបញ្ហាអំពើហិង្សាក្នុង

គ្រួសារ។ ប៉ុន្តែ ច្បាប់នេះនៅតែពុំទាន់ត្រូវបានអនុវត្តឱ្យបានទូលំទូលាយនៅឡើយទេ។ បញ្ហានេះ អាស្រ័យដោយមានបញ្ហាការប្រើប្រាស់ពាក្យពេចន៍មួយចំនួននៅក្នុងច្បាប់នេះ - ចំណុចសំខាន់ គឺវាពុំបានបញ្ជាក់ ឱ្យបានច្បាស់ថាតើអាជ្ញាធរណាមួយជាអ្នកទទួលខុសត្រូវក្នុងការចាត់វិធានការជាបន្ទាន់ ដើម្បីអន្តរាគមន៍ក្នុងករណីអំពើហិង្សាក្នុងគ្រួសារ ក៏ដូចជាជំនឿសង្គម និង វប្បធម៌ហិង្សាដែលកើតមានគ្រប់ទីកន្លែង។ ជំនឿដែលគេជឿជាក់ថា ស្ត្រីកម្ពុជាជាស្ត្រីទន់ជ្រាយ នោះវាបានធ្វើឱ្យជួបការលំបាកក្នុងការទទួលស្គាល់ថា អំពើហិង្សាក្នុងគ្រួសារជាបញ្ហាធ្ងន់ធ្ងរមួយដែលគ្រួសារ មិត្តភ័ក្តិ និង អាជ្ញាធរនានាគួរតែធ្វើអន្តរាគមន៍។ តម្រូវការជាបន្ទាន់មួយ គឺយុទ្ធនាការគាំទ្រដោយរាជរដ្ឋាភិបាល ដើម្បីអប់រំសាធារណជនទូទៅ និង មន្ត្រីអនុវត្តច្បាប់ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ។

## អំពើរំលោភសេពសន្ថវៈ

ជាបទឧក្រិដ្ឋមួយដែលធ្ងន់ធ្ងរជាងគេបំផុតក្នុងចំណោមបទឧក្រិដ្ឋនានាប្រព្រឹត្តមកលើស្ត្រីកម្ពុជាដែលស្ទើរតែត្រូវបានគេមើលរំលងទាំងស្រុងនៅក្នុងសង្គមកម្ពុជា ព្រមទាំងក្នុងជួររាជរដ្ឋាភិបាលផងដែរ។ អំពើរំលោភសេពសន្ថវៈបានដក់ជាប់នៅក្នុងស្ត្រីកម្ពុជាយ៉ាងច្រើន ជាពិសេសស្ត្រីទាំងឡាយដែលមាន ឬ គ្មានមធ្យោបាយដោះស្រាយបញ្ហានេះតាមផ្លូវច្បាប់ ឬ បញ្ហាសង្គម។ វាជាបទឧក្រិដ្ឋមួយដែលត្រូវបានបង្ហាញពីលក្ខណៈដោយការសងជម្ងឺចិត្តខុសច្បាប់ អំពើពុករលួយ និង និទ្ទណ្ឌភាព ដោយជនល្មើសភាគច្រើន ជាទូទៅសងជម្ងឺចិត្តដល់ជនរងគ្រោះ ព្រមទាំងសូកអាជ្ញាធរអនុវត្តច្បាប់ និង តុលាការជាដើម ដើម្បីឱ្យបានគេចផុតពីទណ្ឌកម្ម។ ប្រព័ន្ធបែបនេះបានធ្វើឱ្យជនរងគ្រោះមានភាពឯកកោ គ្មានការជួយឧបត្ថមគាំទ្រ ហើយអនុញ្ញាតឱ្យជនល្មើសគេចផុតពីសំណាញ់ច្បាប់។ លើសពីនេះទៅទៀត វប្បធម៌ខ្មែរបានដក់ជាប់នូវរបត់គំនិតមួយដែលគេយល់ថា អំពើរំលោភសេពសន្ថវៈ គឺជាកំហុសរបស់ស្ត្រីរងគ្រោះ។ ជាការចាំបាច់ណាស់ ដែលរាជរដ្ឋាភិបាលត្រូវតែអប់រំសាធារណជនទូទៅ និង មន្ត្រីអនុវត្តច្បាប់នានាដើម្បីឱ្យពួកគេយល់ថា ករណីរំលោភសេពសន្ថវៈគឺ ជាបទឧក្រិដ្ឋធ្ងន់ធ្ងរមួយ ហើយត្រូវផ្តន្ទាទោសឱ្យស្របតាមច្បាប់កំណត់ ដោយមិនត្រូវទម្លាក់កំហុសលើជនរងគ្រោះទេ។

## អំពើជួញដូរមនុស្ស ដើម្បីគោលបំណងអាជីវកម្មផ្លូវភេទ

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រភព ជាតំបន់ឆ្លងកាត់ និងជាប្រទេសទីដៅចុងក្រោយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីគោលបំណងផ្លូវភេទ។ រាជរដ្ឋាភិបាលបានទទួលស្គាល់ថា មានការកើនឡើងយ៉ាងខ្លាំងនូវស្ថានភាពនេះ ក៏ប៉ុន្តែខ្លួននៅតែចាត់វិធានការទប់ទល់នឹងបញ្ហានេះក្នុងកំរិតទាបនៅឡើយ។ ច្បាប់ប្រឆាំងអំពើជួញដូរមនុស្ស បច្ចុប្បន្នមិនត្រូវបានអនុវត្តឱ្យបានខ្លាំងក្លាទេ ហើយថែមទាំងមានការពន្យាពេលក្នុងការអនុម័តសេចក្តីព្រាងច្បាប់ថ្មីស្តីពីអំពើជួញដូរមនុស្ស និង អាជីវកម្មផ្លូវភេទផង។ ទោះបីជាច្បាប់ថ្មីត្រូវបានអនុម័តរួចហើយក្តី

ក៏នៅតែមានផលប៉ះពាល់តិចតួចដដែលក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ប្រសិនបើពុំមានការប្តេជ្ញាដោយមុឹងម៉ាត់ ដើម្បីអនុវត្តច្បាប់ទេនោះ។ អំពើពុករលួយនៅកម្ពុជា និង ផលចំណេញយ៉ាងក្រាស់ក្រែលនៃមុខរបរជួញដូរមនុស្ស នោះមានន័យថាជនល្មើសអាចសូក ដើម្បីបើកផ្លូវគេចឱ្យផុតពីការប្រឈមជាមួយច្បាប់។ នគរបាល កងរាជអាវុធហត្ថ និង មន្ត្រីរាជរដ្ឋាភិបាលមួយចំនួនតូច ត្រូវបានគេជឿជាក់ជាទូទៅថា មានការពាក់ព័ន្ធនៅគ្រប់កំរិតនៃអំពើជួញដូរមនុស្ស និង ពេស្យាចារដោយបង្ខំនៅកម្ពុជា។ និទ្ទណ្ឌភាពនេះ តើត្រូវឋិតថេររហូតដល់ពេលណា ទើបត្រូវបានដោះស្រាយដោយរាជរដ្ឋាភិបាល និងជនល្មើសត្រូវបានផ្តន្ទាទោសដោយពុំយល់មុខនរណាម្នាក់ ប៉ុន្តែស្ថានភាពទាំងនេះនៅតែដូចមុនដដែល។

## អនុសាសន៍

អ្វីជាតម្រូវការចាំបាច់ ដើម្បីកាត់បន្ថយអំពើហិង្សាមកលើស្ត្រីទាំងឡាយ នោះពុំមែនវោហាសាស្ត្រដែលបញ្ចេញដោយរាជរដ្ឋាភិបាលទៀតទេ ប៉ុន្តែគឺជាវិធានការជាក់លាក់ទៅវិញ។ ត្រូវដើរតាម នឹងអនុវត្តច្បាប់បច្ចុប្បន្ននេះ។ ក្នុងករណីចាំបាច់ ច្បាប់មួយចំនួនគួរតែធ្វើការកែតម្រូវ ហើយជាពិសេស កិច្ចប្រតិបត្តិច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ គួរតែត្រូវបានបំភ្លឺ ហើយសេចក្តីព្រាងច្បាប់ស្តីពីអំពើជួញដូរមនុស្ស និង អាជីវកម្មផ្លូវភេទគួរតែត្រូវបានអនុម័ត ប៉ុន្តែតម្រូវការច្បាប់ថ្មី មិនគួរត្រូវប្រើជាលេស ដើម្បីដោះសារដោយមិនអនុវត្តច្បាប់បច្ចុប្បន្ននោះទេ។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលត្រូវតែផ្តួចផ្តើមបង្កើតគោលនយោបាយជាក់លាក់ ដើម្បីដោះស្រាយអំពើហិង្សាលើស្ត្រីដែលមានលក្ខណៈជាប្រព័ន្ធ រួមមានយុទ្ធនាការអប់រំ ដើម្បីប្រយុទ្ធប្រឆាំងនឹងឥរិយាបទសង្គម និងវប្បធម៌ចំពោះអំពើរំលោភសេពសន្ថវៈ និង អំពើហិង្សាក្នុងគ្រួសារ។ រាជរដ្ឋាភិបាលមានកាតព្វកិច្ចមួយក្នុងការប្រមូលកិច្ចប្រឹងប្រែងរួម ដើម្បីអនុវត្តច្បាប់ និង គោលនយោបាយទាំងនេះក្នុងកាលកំណត់ជាក់លាក់មួយ។ ប្រសិនបើរាជរដ្ឋាភិបាលមិនធ្វើឱ្យបានតាមកាលកំណត់នេះទេ នេះបង្ហាញពីភាពបរាជ័យដែលត្រូវទទួលខុសត្រូវចំពោះមុខសហគមន៍អន្តរជាតិនិងសង្គមស៊ីវិលនៅកម្ពុជាក្នុងភារកិច្ចសម្រេចនូវគោលដៅទាំងនេះ។

# ១. បុព្វកថា

ក្នុងឆ្នាំ ២០០៦ អង្គការលីកាដូបានទទួលបណ្តឹងជាង ៣០០ ករណីពីស្ត្រីកម្ពុជា ស្តីពីអំពើហិង្សាក្នុងគ្រួសារ អំពើរំលោភសេពសន្ថវៈ និង បៀតបៀនកេរ្តិ៍ខ្មាស ឬ អំពើជួញដូរមនុស្ស ដើម្បីគោលបំណងអាជីវកម្មផ្លូវភេទ។ ក្នុងរយៈពេល ៣ ឆ្នាំ កន្លងមកនេះ របាយការណ៍ស្តីពីអំពើហិង្សានេះមានការកើនឡើងជាលំដាប់។ គេពិបាកវាស់វែងណាស់ ដើម្បីឱ្យដឹងថា តើការយល់ដឹងអំពីសិទ្ធិស្ត្រី និង ច្បាប់ខ្ពស់ជាងមុន ឬ នៅស្មើដដែល។ ប៉ុន្តែ គេអាចដឹងច្បាស់ថា ទោះបីជាមូលហេតុអ្វីក៏ដោយនៅពីក្រោយកំណើនរបាយការណ៍នេះ អំពើហិង្សាលើស្ត្រីគឺ ជាបញ្ហាដ៏ធ្ងន់ធ្ងរ ហើយជារៀងរាល់ឆ្នាំស្ត្រីកម្ពុជាជាច្រើនទទួលរងគ្រោះដោយសារតែអំពើហិង្សានេះ។

ចាប់តាំងពី ឆ្នាំ២០០១ អង្គការលីកាដូបានចេញផ្សាយរបាយការណ៍ជាច្រើនស្តីអំពីសិទ្ធិស្ត្រីនៅកម្ពុជាដែលរួមមានអំពើរំលោភសេពសន្ថវៈនិងបៀតបៀនកេរ្តិ៍ខ្មាសនៅកម្ពុជា ស្ថានភាពស្ត្រីនៅកម្ពុជា និង អំពើហិង្សាលើស្ត្រីនៅកម្ពុជា។ របាយការណ៍ទាំងនេះបានគូសបញ្ជាក់អំពីអំពើហិង្សាលើស្ត្រីដ៏ធ្ងន់ធ្ងរជាទីបំផុតហើយថែមទាំងបានផ្តល់នូវអនុសាសន៍ជាច្រើន ដើម្បីសំណូមពរផ្លាស់ប្តូរឱ្យស្ថានភាពស្ត្រីកម្ពុជាប្រសើរជាងមុន។



របាយការណ៍នេះមានគោលបំណង ដើម្បីផ្តល់នូវទិន្នន័យរងគ្រោះជាក់លាក់ ដែលស្ត្រីកម្ពុជាបានរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ រំលោភសេពសន្ថវៈ និងជួញដូរមនុស្សក្នុងគោលបំណងអាជីវកម្មផ្លូវភេទ។ របាយការណ៍បានផ្អែកទៅលើព័ត៌មានពីការិយាល័យការពារសិទ្ធិស្ត្រីនៃអង្គការលីកាដូ នៅភ្នំពេញ និង បុគ្គលិកនៅការិយាល័យខេត្តចំនួន ១២ទៀត ហើយនៅក្នុងរបាយការណ៍ក៏មានសាច់រឿងផ្ទាល់ខ្លួនពិត ស្តីពីអំពើហិង្សារបស់ស្ត្រី៤នាក់ផងដែរ។ តាមរយៈការដកស្រង់សំដី ការសង្កេតពីជនរងគ្រោះ និង របាយការណ៍របស់អ្នកស៊ើបអង្កេតលីកាដូនានា រឿងរ៉ាវទាំងនេះត្រូវបានរៀបរាប់ប្រាប់ជាមនុស្សទីមួយ ដោយប្រើនូវអត្តសញ្ញាណប្រឌិត ដើម្បីលាក់អនាមិកភាពជូនជនរងគ្រោះ ។

ដោយរួមមានការកែសំរួលពាក្យសំដីនៅក្នុងប្រភេទនៃអំពើហិង្សាលើស្ត្រីខ្លះ១ផងដែរ ដែលជាការឆ្លើយតបរបស់រាជរដ្ឋាភិបាលចំពោះបញ្ហាទាំងឡាយ និងទិន្នន័យស្ថិតិករណីដែលបានរាយការណ៍មកលីកាដូនៅក្នុងឆ្នាំ ២០០៦។

គោលបំណងនៃរបាយការណ៍នេះ គឺសំដៅទៅលើសហគមន៍អន្តរជាតិ និង សង្គមស៊ីវិលនៅកម្ពុជា ដើម្បីឱ្យមានឥទ្ធិពលលើរាជរដ្ឋាភិបាលកម្ពុជាឈានទៅសម្រេចកាតព្វកិច្ចរបស់ខ្លួនតាមអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី និង គោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា អំពីបញ្ហាអំពើហិង្សាលើស្ត្រី ។

គោលដៅអភិវឌ្ឍន៍សហសវត្ស ៣ គោលដៅរួម ៨ ចែងថា រាជរដ្ឋាភិបាលនឹងកាត់បន្ថយឱ្យបានជាអតិបរមានូវរាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី និង កុមារដោយអនុវត្តនូវភារកិច្ចដូចខាងក្រោម :

- បង្កើនសមាមាត្រករណីអំពើហិង្សាក្នុងគ្រួសារ ឱ្យមានការពិគ្រោះយោបល់ដោយបុគ្គលិកមានសមត្ថភាពរហូត ១០០ ត្រឹមឆ្នាំ ២០១៥ ។
- បង្កើនភាគរយប្រជាពលរដ្ឋឱ្យមានការយល់ដឹងនូវអំពើហិង្សាលើស្ត្រីថាជាអំពើខុសច្បាប់ និងជាអំពើឧក្រិដ្ឋឱ្យដល់ ១០០ ត្រឹម ឆ្នាំ២០០៥ ។
- តាក់តែង និង អនុវត្តច្បាប់ប្រឆាំងនូវរាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី និង កុមារដោយអនុលោម ទៅតាមបទដ្ឋាន និង តម្រូវការអន្តរជាតិ ត្រឹមឆ្នាំ ២០០៥ ។
- ប្រមូលស្ថិតិប្រចាំឆ្នាំ ដើម្បីត្រួតពិនិត្យអំពើហិង្សាលើស្ត្រីត្រឹមឆ្នាំ ២០០៥ ។
- តាក់តែង និង អនុវត្តផែនការទប់ស្កាត់ត្រឹមឆ្នាំ ២០០៥ ។



នៅក្នុងរបាយការណ៍នេះ រឿងរ៉ាវរបស់**ស្រី មុំ លី វីជែន ជេត** និង **ហេង ណារី** គឺជារឿងពិតដែលលាតត្រដាងនូវអំពើហិង្សាដោយផ្អែកលើសំដីរបស់ជនរងគ្រោះ និង ការស៊ើបអង្កេតដោយបុគ្គលិកស៊ើបអង្កេតអង្គការលីកាដូ ក្នុងឆ្នាំ២០០៦ កន្លងទៅនេះ ។ ខ្លឹមសារនៃរឿងនីមួយៗ ត្រូវបានដកស្រង់ចេញពីការសម្ភាសន៍ជាមួយនឹងជនរងគ្រោះទាំងនេះ និង ការស៊ើបអង្កេតដោយបុគ្គលិកស៊ើបអង្កេតលីកាដូ ។ រឿងរ៉ាវរបស់ស្ត្រី ៤ រូបនេះត្រូវជ្រើសរើសពីព្រោះករណីរបស់ពួកគេ អាចជាតំណាងឱ្យអំពើហិង្សាលើស្ត្រីនៅកម្ពុជា និង ជាការចែករំលែកនូវរឿងប្រហាក់ប្រហែលគ្នានេះជាមួយស្ត្រីទាំងឡាយដែលបានមកប្ដឹង និង រាយការណ៍ប្រាប់អង្គការលីកាដូ ។

ឈ្មោះ និង អត្តសញ្ញាណទាំងឡាយនៅក្នុងសាច់រឿងត្រូវបានផ្លាស់ប្តូរ ដើម្បីលាក់អត្តសញ្ញាណជូនជនរងគ្រោះរបស់យើង ។ ដោយរឿងទាំងនេះផ្អែកលើបទពិសោធន៍ជាក់ស្តែងរបស់ជនរងគ្រោះ ប៉ុន្តែក៏មានការបន្ថែមនូវការរៀបរៀងសាច់រឿងខ្លះៗ ដើម្បីបង្ហាញនូវសាច់រឿងឱ្យមានភាពពេញលេញជាងមុន ។

# ២. អំពើហិង្សាក្នុងគ្រួសារ

**ក្នុងជំពូកនេះ...**

**ករណីសិក្សា ១: អំពើហិង្សាក្នុងគ្រួសារ**

**បញ្ហាអំពើហិង្សាក្នុងគ្រួសារ: រឿងរ៉ាវរបស់ស្រី មុំ**

- *វប្បធម៌អន់ថយ*
- *វដ្តនៃអំពើហិង្សាក្នុងគ្រួសារ*
- *តើមានជំនួយអ្វីខ្លះសម្រាប់ស្រីមុំ?*
- *ច្បាប់អំពើហិង្សាក្នុងគ្រួសារ*

**ករណីអំពើហិង្សាក្នុងគ្រួសារដែលបានរាយការណ៍**

**ការឆ្លើយតបរបស់រាជរដ្ឋាភិបាលចំពោះអំពើហិង្សា ក្នុងគ្រួសារ**

ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ[១] បានឱ្យនិយមន័យពាក្យអំពើហិង្សាក្នុងគ្រួសារដូចខាងក្រោមៈ[២]

- អំពើដែលប៉ះពាល់ដល់អាយុជីវិត
- អំពើដែលប៉ះពាល់ដល់អធិបតេយ្យភាពរាងកាយ
- អំពើទារុណកម្ម ឬ អំពើសាហាវព្រៃផ្សៃ
- ការរំខានដែលបណ្តាលឱ្យមានទុក្ខទោសដល់ផ្នែកផ្លូវចិត្ត រាងកាយ អារម្មណ៍ ប្រាជ្ញាស្មារតី
- ការធ្វើទុក្ខទោសខាងផ្លូវចិត្ត/ចិត្តសាស្ត្រ រាងកាយ និង ដែលប្រព្រឹត្តហួសព្រំដែនសីលធម៌ និង ច្បាប់
- ការបំពារបំពានខាងផ្លូវភេទ (រួមមានហិង្សាផ្លូវភេទ ការរំខានផ្លូវភេទ និង ការបៀតបៀនផ្លូវភេទជាដើម) ។
- ការគំរាមកំហែងដែលមានគោលបំណង ដើម្បីបំភិតបំភ័យធ្វើឱ្យតក់ស្លុត ។
- អំពើដែលនាំឱ្យប៉ះពាល់ដល់បុគ្គល និង ទ្រព្យសម្បត្តិ ។

ច្បាប់ការពារប្តី ប្រពន្ធ កូនៗក្នុងបន្ទុក និង សមាជិកផ្សេងទៀតដែលរស់នៅក្រោមដំបូលតែមួយ ព្រមទាំងមនុស្សទាំងអស់ក្នុងផ្ទះ[៣] ។

---

[១] អនុម័តដោយរាជរដ្ឋាភិបាលកម្ពុជាកាលពីថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០០៥។ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ ជាការបំពេញច្បាប់ដែលមានស្រាប់កំពុងប្រើប្រាស់ដើម្បីការពារជនរងគ្រោះដោយ អំពើហិង្សាក្នុង គ្រួសារនៅកម្ពុជា។ សូមមើលឯកសារ" ហិង្សាលើស្ត្រីនៅកម្ពុជា (សរសេរដោយអ្នកស្រី ចូ អាន លីម អង្គការលីកាដូ ទំព័រ ៤) សម្រាប់ជាព័ត៌មានបន្ថែម ។

[២] មាត្រា ៣ - ៧ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ ។

[៣] មាត្រា ២ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ ។

## ករណីសិក្សា ១ : អំពើហិង្សាក្នុងគ្រួសារ - ការវាយដំអស់រយៈពេលយ៉ាងយូរ

*ខ្ញុំឈ្មោះ ស្រី មុំ អាយុ ៤២ឆ្នាំ ប្តីខ្ញុំតែងតែវាយធ្វើបាបខ្ញុំជាប្រចាំ ។ ខាងក្រោមនេះ ជារឿងរ៉ាវរបស់ខ្ញុំ ។*

*ខ្ញុំបានរៀបការជាមួយប្តីខ្ញុំឈ្មោះ សុខលី តាំងពីខ្ញុំអាយុ ១៩ឆ្នាំ ។ កាលនោះខ្ញុំសប្បាយចិត្តណាស់នៅពេលរៀបការដោយខ្ញុំគិតឃើញថា ខ្ញុំនឹងមានជីវិតថ្មីជាមួយ សុខ លី និង កូនៗដែលយើងនឹងមាន ។*

*ប្រហែលជាមួយឆ្នាំក្រោយមក ខ្ញុំចាប់ផ្តើមមានផ្ទៃពោះ ហើយប្រសូត្របានកូនជាលើកដំបូងរបស់យើង ។ ខ្ញុំមានការសប្បាយចិត្តយ៉ាងខ្លាំង ប៉ុន្តែសុខលី គាត់ចង់រកស៊ីឱ្យបានលុយច្រើន ដើម្បីចិញ្ចឹមកូនរបស់យើង ហើយគាត់ក៏ចេញទៅធ្វើការនៅខេត្តផ្សេង ។ ខ្ញុំពុំចាំបានថា គាត់ធ្វើការងារអ្វីទេ ដោយគាត់គ្រាន់តែផ្ញើលុយបន្តិចបន្តួចតែប៉ុណ្ណោះមកឱ្យខ្ញុំ និង កូន ក្នុងរយៈពេល ២-៣ ខែម្តង ។ ពេលនោះឪពុក-ម្តាយខ្ញុំបានជួយផ្គត់ផ្គង់ដល់កូនខ្ញុំ និង ខ្ញុំ ។ មួយឆ្នាំក្រោយមក សុខលី បានត្រឡប់មកផ្ទះវិញ ហើយពុំមានការងារធ្វើសោះ ។ ពេលនោះខ្ញុំដើរស៊ីឈ្នួលបោកគក់ខោអាវឱ្យគេ ដើម្បីយកលុយទិញអង្ករញ៉ាំ ហើយនេះជាកិច្ចការលំបាកណាស់ ។*

### ***ការបោះបង់ចោល***

*ក្រោយមកខ្ញុំក៏បានប្រសូត្រកូនទី២ទៀត គ្រានោះ សុខលី ក៏បានចុះចោលខ្ញុំម្តងទៀត -ដោយគាត់ពុំមែនទៅធ្វើការរកស៊ីទេ ប៉ុន្តែគាត់ទៅរស់នៅជាមួយស្រីកំណាន់របស់គាត់នៅខេត្តផ្សេង ។ ខ្ញុំមានការតូចចិត្ត នឹងសោកសង្រេងយ៉ាងខ្លាំងដោយសាររឿងនេះ ។ ខ្ញុំពុំយល់ថា ហេតុអ្វីបានជាសុខលីធ្វើបែបនេះដាក់ខ្ញុំ ហើយខ្ញុំតែងតែបន់ឱ្យគាត់ត្រឡប់មកផ្ទះវិញ ។ ឪពុក-ម្តាយខ្ញុំប្រាប់ខ្ញុំថា គាត់នៅតែជាប្តីរបស់ខ្ញុំដដែល ហើយនិយាយថា ខ្ញុំជាមនុស្សមានសំណាងហើយដែលបានរៀបការ ថែមទាំងមានកូនពីរទៀត ហើយគាត់ថា ខ្ញុំមិនគួរធ្វើអ្វីឱ្យមានបញ្ហាជាមួយសុខលី ឬក៏ខឹងគាត់ទេ ។ ខ្ញុំសប្បាយចិត្តណាស់ ដែលខ្ញុំបានស្តាប់តាមដំបូន្មានរបស់ឪពុក-ម្តាយខ្ញុំ ពីព្រោះ ៤ ឆ្នាំក្រោយមក-សុខលីត្រឡប់មកផ្ទះវិញ ។ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ហើយក៏សប្បាយចិត្តផង ហើយពេលនេះខ្ញុំគិតថា ខ្ញុំនឹងធ្វើជាប្រពន្ធដ៏ល្អរបស់គាត់ មិនឱ្យដូចមុនៗទៀតទេ ព្រមទាំងតាំងចិត្តថា ធ្វើជាផ្ទះមេដ៏ល្អសម្រាប់សុខលី និង កូនៗផងដែរ ។*

*មួយរយៈក្រោយមកខ្ញុំក៏បានប្រសូត្រកូនមួយទៀត ហើយហេតុការណ៍មុនៗនៅតែដដែល សុខលី បានចុះបោលខ្ញុំ ជាថ្មីម្តងទៀត ទៅរស់នៅជាមួយស្រីកំណាន់របស់គាត់ ។ ពេលដែលគាត់ត្រឡប់មកវិញ ខ្ញុំទាយថា គាត់ពិតជាអស់លុយរលីងហើយ ។ ស្ថានភាពបែបនេះ ខ្ញុំដើរស៊ីឈ្នួលបោកសម្លៀកបំពាក់ឱ្យគេជាប្រចាំ-ដើម្បីរកចំណូលបានល្មមនឹងចិញ្ចឹមកូន និងខ្លួនខ្ញុំ ប៉ុន្តែពុំអាចមានលទ្ធភាពឱ្យកូនធំទៅរៀនសាលាបានទេ ។ ខ្ញុំមានវិប្បដិសារីជាខ្លាំងស្តីអំពីបញ្ហានេះ ។*

## ***អំពើហិង្សាលើរាងកាយ***

*ខ្ញុំគិតថា ខ្ញុំមានការផ្លាស់ប្តូរខ្លះៗក្រោយពី សុខលី ចុះចោលខ្ញុំនៅលើកទី២ ។ ខ្ញុំមានអារម្មណ៍ខឹងគាត់ ហើយមិនសូវសប្បាយចិត្តប៉ុន្មានទេ នៅពេលដែលឃើញគាត់ត្រឡប់មកវិញ ហើយខ្ញុំក៏មិនចង់អភ័យទោសឱ្យគាត់ដែរ ចំពោះរឿងដែលគាត់ចុះចោលគ្រួសារទៅរស់នៅជាមួយស្រីកំណាន់នេះ ។ ប៉ុន្តែ ខ្ញុំចេះតែខ្លាចថា គាត់ចុះចោលយើងទៀត ហើយពេលនេះ ខ្ញុំត្រូវពន្យល់កូនៗរបស់ខ្ញុំអំពីបញ្ហានេះ ថាហេតុអ្វីបានជាឪពុករបស់ពួកគេចេះតែចុះចោលពួកយើងដូច្នេះ ។ ឪពុក-ម្តាយខ្ញុំនៅតែប្រាប់ខ្ញុំថា ឱ្យធ្វើចិត្តសប្បាយៗទៅ ដើម្បីជៀសវាងបញ្ហាជាមួយ សុខលី ឬ ខឹងជាមួយគាត់ឱ្យសោះ ។ ពួកគាត់និយាយថា សុខលី គឺជាឪពុករបស់កូនទាំង ៣ របស់ខ្ញុំ ហើយអ្វីសំខាន់ជាងនេះទៅទៀត គាត់គឺជាប្តីរបស់ខ្ញុំ ហេតុនេះខ្ញុំត្រូវតែគោរពគាត់ ។ ប៉ុន្តែខ្ញុំខឹងខ្លាំងណាស់ ហើយមិនចង់ស្តាប់ដំបូន្មានអ្វីទៀតទេ ។ ថ្ងៃមួយ ខ្ញុំចូលមកដល់ផ្ទះក្រោយពីបោកគក់សម្លៀកបំពាក់ជាច្រើន ។ ខ្ញុំអស់កម្លាំង និងហេវហត់យ៉ាងខ្លាំង ។ សុខលីនៅក្នុងផ្ទះ ដោយអាការស្រវឹងស្រា ។ ខ្ញុំខឹងគាត់យ៉ាងខ្លាំង ពីព្រោះគាត់ស្រវឹងស្រាខ្ជប និងរឿងចុះចោលផ្ទះម្តងហើយម្តងទៀត ដោយមិនប្រកបរបររកស៊ី ហើយទារតែលុយដែលខ្ញុំខំរកបានតិចតួចសម្រាប់ចិញ្ចឹមកូនៗ យកទៅផឹកស្រា ។ ខ្ញុំក៏បានស្រែកដាក់គាត់ ហើយគាត់ក៏ខឹងខ្ញុំយ៉ាងខ្លាំង គាត់ស្ទុះទៅចាប់យកដំបងឬស្សីមួយវាយខ្ញុំ ។ ខ្ញុំខំប្រឹងរត់គេចឱ្យឆ្ងាយ ប៉ុន្តែរត់មិនរួចសោះ ។ គាត់វាយត្រូវជើងខាងឆ្វេង ខ្ញុំឈឺចុកចាប់យ៉ាងខ្លាំង ។ ពេលដែលគេសួរខ្ញុំថា ហេតុអ្វីជើងមានឈាម ខ្ញុំកុហក់គេថា ខ្ញុំដើរដួល ដោយដើរមិនប្រយ័ត្ន ។ មានតែកូនៗខ្ញុំទេដែលដឹងរឿងនេះ ។*

*បន្ទាប់ពីពេលនោះមក ខ្ញុំចេះតែខ្លាចសុខលី ប៉ុន្តែខ្ញុំចេះតែព្យាយាមធ្វើជាប្រពន្ធល្អ ។ ខ្ញុំគិតថា នេះជាកំហុសរបស់ខ្ញុំទេ ដែលគាត់ស្រវឹងដូច្នេះ ហើយមិនធ្វើការ ។ ដូច្នេះខ្ញុំក៏ខំប្រឹងធ្វើយ៉ាងណាឱ្យសុខលីសប្បាយចិត្ត ។ រយៈពេលក្រោយមក ខ្ញុំក៏មានផ្ទៃពោះ ហើយប្រសូត្របានកូនទី ៤ ។*

## ***ការប៉ុនប៉ងសម្លាប់***

*ពេលនោះជីវិតរបស់យើងក្លាយជាសុបិន្តអាក្រក់មួយ ។ សុខលីផឹកស្រាស្រវឹងជារៀងរាល់ថ្ងៃ ហើយរក*

រឿងឈ្លោះប្រកែកជាមួយខ្ញុំជាប្រចាំ។ គាត់និយាយថា ខ្ញុំគ្មានតម្លៃអ្វីសម្រាប់គាត់ទេ ហើយខ្ញុំនេះជាម្ដាយ និង ជាប្រពន្ធអាក្រក់ដែលមិនចេះបំពេញចិត្តប្ដី អញ្ចឹងហើយបានជាគាត់ចេះតែចុះចោលផ្ទះទៅរស់នៅជាមួយស្រីដូច្នេះ។ ពេលនោះខ្ញុំកាន់តែខ្លាចគាត់ខ្លាំងជាងមុន ហើយខ្ញុំមិននិយាយរឿងនេះប្រាប់អ្នកណាទេ ដើម្បីកូនៗ ខ្ញុំចេះតែលាក់រឿងនេះរហូត។ ថ្ងៃមួយគាត់ស្រវឹងស្រាយ៉ាងខ្លាំង ខ្ញុំដឹងថាគាត់ប្រាកដជាវាយខ្ញុំទៀតហើយ។ គាត់ទាញកាំបិតមកកាន់នៅដៃ ហើយប្រុងចាក់ខ្ញុំ។ កូនៗស្រែកទ្រហោយំពេញផ្ទះ អង្វរគាត់កុំឱ្យធ្វើបាបខ្ញុំ។ ពេលនោះខ្ញុំចេះតែព្យាយាមរត់គេចចេញឱ្យឆ្ងាយពីគាត់។ ប៉ុន្តែគាត់ចាប់យកពូថៅ ហើយបម្រុងនឹងកាប់ខ្ញុំទៀត។ ខ្ញុំគិតថានេះដោយសារតែគាត់ស្រវឹង គាត់កាប់ខ្ញុំខុសជាច្រើនដង ហេតុនេះទើបខ្ញុំទាញដៃកូនៗរត់ចេញបាន។ ខ្ញុំនាំកូនរត់ទៅផ្ទះឪពុក-ម្ដាយខ្ញុំ ហើយខ្ញុំសុំគាត់ ឱ្យខ្ញុំ និង កូនៗស្នាក់នៅផង ហើយខ្ញុំក៏បានសុំគាត់លែងប្ដីថែមទៀត។ ខ្ញុំបានរៀបរាប់ប្រាប់ឪពុក-ម្ដាយខ្ញុំអំពីរឿងសុខលី ដែលពីមួយថ្ងៃទៅមួយថ្ងៃកាន់តែប្រើហិង្សាដាក់ខ្លាំងឡើងៗ ហើយអ្វីដែលធ្វើឱ្យខ្ញុំខ្លាចទៀតនោះ គឺគាត់ព្យាយាមចង់សម្លាប់ខ្ញុំ។ ពេលនោះ ឪពុក-ម្ដាយខ្ញុំក៏ឱ្យពួកខ្ញុំស្នាក់នៅផ្ទះគាត់ ១ យប់ ហើយគាត់គិតថាព្រឹកឡើងពួកយើងនឹងត្រឡប់ទៅរក សុខលីវិញ និងបន្តរស់នៅជាប្ដីប្រពន្ធតទៅទៀត។ ពួកគាត់ប្រាប់ខ្ញុំយ៉ាងច្បាស់ថា កុំឱ្យនិយាយរឿងនេះប្រាប់អ្នកណាឱ្យសោះ។ ហេតុនេះ ព្រឹកឡើងខ្ញុំ និង កូនៗក៏ត្រឡប់ទៅផ្ទះវិញ។

ក្រោយមក ខ្ញុំក៏មានផ្ទៃពោះកូនទី ៥ ដែលជាកូនពៅ។ ក្នុងកំឡុងពេលមានផ្ទៃពោះនោះខ្ញុំមានការភ័យខ្លាចយ៉ាងខ្លាំង។ ខ្ញុំមិនហ៊ាននៅជាមួយសុខលី តែម្នាក់ឯងទេ ពីព្រោះខ្ញុំមានការបារម្ភខ្លាចគាត់វាយធ្វើបាបខ្ញុំក្នុងអំឡុងពេលដែលខ្ញុំមានផ្ទៃពោះ។ ពីរសប្ដាហ៍ក្រោយពេលខ្ញុំសម្រាលកូនពៅហើយ ខ្ញុំនៅក្នុងផ្ទះកំពុងដេកជាមួយកូនតូច ពេលកូនធំៗកំពុងលេងក្បែរៗផ្ទះនៅខាងក្រៅ។ ស្រាប់តែខ្ញុំភ្ញាក់ឡើង ដោយធុំក្លិនឈ្ងៀមផ្សែង។ ខ្ញុំគិតថា អ្នកណាដាំស្លជិតៗនេះឯង។ ខ្ញុំបីកូនតូចដើរសំដៅទ្វារ ហើយស្រែកឡើង—ផ្សែងខ្លាំងណាស់ ភ្លើងឆេះផ្ទះហើយ។ ខ្ញុំរត់ចេញក្រៅផ្ទះ ហើយឃើញសុខលីនៅខាងក្រៅ សម្លឹងមើលមុខខ្ញុំ ដោយទឹកមុខចម្លែក។ ក្រោយពីអ្នកជិតខាងបានជួយពន្លត់ភ្លើងរួចរាល់ ទើបខ្ញុំដឹងថា សុខលីជាអ្នកដុតផ្ទះនេះ ព្រោះគាត់ដឹងថា ខ្ញុំកំពុងនៅក្នុងផ្ទះជាមួយកូនតូច។ ដូច្នេះខ្ញុំគិតថា គាត់មានបំណងចង់សម្លាប់ខ្ញុំប្រាកដណាស់ ។

## ស្វែងរកឱ្យគេជួយ

សុខលីចាប់ផ្ដើមវាយដំខ្ញុំទៀតក្រោយពីដុតផ្ទះរួច ព្រោះខឹងខ្ញុំពុំបានស្ងោរមាន់ឱ្យគាត់បរិភោគ ឬដោយយកលេសថា ខ្ញុំគិតលុយចំណាយខុស និង ដោយសារកំហុសផ្សេងៗទៀតដែលខ្ញុំបានធ្វើមិនគប្បីចំពោះគាត់។ អ្វីដែលអាក្រក់បំផុតនោះគឺ គាត់វាយកូនៗថែមទៀត។ ខ្ញុំគិតថា ខ្ញុំបន្តរស់នៅជាមួយគាត់តទៅទៀត ហើយមិននិយាយពីរឿងនេះទេ ប្រសិនបើគាត់វាយខ្ញុំ។ ប៉ុន្តែខ្ញុំមិនអាចឱ្យគាត់វាយធ្វើបាបកូនៗខ្ញុំបានទេ។ ថ្ងៃមួយគាត់វាយ

*កូនស្រី អាយុ ១៨ឆ្នាំ យ៉ាងខ្លាំង ដោយគ្មានមូលហេតុអ្វីទាល់តែសោះ ។ កូនត្រូវរបួសយ៉ាងធ្ងន់ ហើយខ្ញុំសម្រេចថា ប៉ុណ្ណឹងល្មមហើយ ដោយមិនត្រូវទុកឱ្យសុខលីវាយកូនៗ និង រូបខ្ញុំទៀតទេ ។ ខ្ញុំនាំកូនស្រីទៅរកអង្គការឱ្យជួយ និង ប្រាប់គេពីអ្វីដែលសុខលីបានប្រព្រឹត្តចំពោះយើងកន្លងមក ។*

*តាំងពីមុនមក ខ្ញុំមិនដែលនិយាយរឿងអំពើហិង្សានេះប្រាប់អាជ្ញាធរណាមួយទេ ក្រោយពីគាត់ព្យាយាមសម្លាប់ និង វាយដំខ្ញុំ ។ ខ្ញុំធ្លាប់និយាយប្រាប់តែឪពុក-ម្តាយខ្ញុំតែប៉ុណ្ណោះ ។ ប៉ុន្តែថ្ងៃនោះ ខ្ញុំគិតថា វាជាពេលវេលាដែលសុខលីត្រូវឈប់វាយធ្វើបាបយើងតទៅទៀតហើយ ។ វាជាពេលដែលខ្ញុំត្រូវតែខ្លាំង ដើម្បីកូនៗរបស់ខ្ញុំ ។ម្យ៉ាងទៀត ដើម្បីឱ្យសុខលីដឹងថា អ្វីដែលគាត់បាននឹងកំពុងធ្វើក្នុងរយៈពេលជាង១០ឆ្នាំនេះ គឺជាកំហុសធ្ងន់ធ្ងរណាស់ ។*

*ខ្ញុំចង់លែងលះសុខលី ។ ខ្ញុំមិនចង់ឱ្យកូនៗខ្ញុំរស់នៅជាមួយគាត់ទេ ។ ខ្ញុំមិនចង់រស់នៅជាមួយគាត់ដែលពោរពេញទៅដោយអារម្មណ៍ភ័យខ្លាច និង មន្ទិលសង្ស័យរាល់ថ្ងៃថា តើគាត់វាយដំខ្ញុំ ឬទេថ្ងៃនេះ? ឬអ្វីដែលអាក្រក់នោះ- តើគាត់ចង់សម្លាប់ខ្ញុំទៀតដែរឬទេ?*



## បញ្ហាអំពើហិង្សាក្នុងគ្រួសារ : រឿងរ៉ាវរបស់ស្រី មុំ

### *វប្បធម៌អន់ថយ*

ដូចស្ត្រីកម្ពុជាផ្សេងៗទៀតដែរ ស្រី មុំ រងគ្រោះនូវអំពើហិង្សាក្នុងគ្រួសារអស់រយៈពេលជាច្រើនឆ្នាំ ដោយមិនដែលនិយាយប្រាប់សាច់ញាតិមិត្តភ័ក្តិ ឬស្វែងរកឱ្យគេជួយឡើយ ។ ភាពអាម៉ាស់ក្នុងការទម្លាយរឿងក្នុងគ្រួសារទៅឱ្យអ្នកក្រៅដឹង គឺជាហេតុគ្រប់គ្រាន់ដែលធ្វើឱ្យស្ត្រីទាំងឡាយលាក់បាំងបញ្ហារបស់ខ្លួន។ លើសពីនេះទៅទៀត វប្បធម៌កម្ពុជាបានជំរុញឱ្យមានវប្បធម៌អន់ថយមួយ ។
ស្ត្រីណាដែលរងនូវអំពើហិង្សាក្នុងគ្រួសារច្រើនតែបន្ទោសខ្លួនឯងថា ជាអ្នកនាំឱ្យប្តី ប្រព្រឹត្តហិង្សា។

កម្ពុជានៅតែប្រកាន់តាមច្បាប់ក្រមសីលធម៌ប្រពៃណី[៤] មួយដែលគេហៅថា "ច្បាប់ស្រី" ដែលចែងថា ស្ត្រីត្រូវតែបម្រើ និង គោរពប្តីរបស់ខ្លួនគ្រប់ពេលវេលា។ ដំបូន្មានទាំងនោះមានដូចជា" មិនត្រូវនិយាយរឿងរបស់ប្តីទៅប្រាប់ឪពុកម្តាយ នោះវាជាការដុតបង្កាត់ភ្លើងឱ្យឆេះ" មិនត្រូវដេកបែរខ្នងដាក់ប្តី ហើយមិនត្រូវយកដៃលេងក្បាល

[៤] ច្បាប់ស្រី ជាក្រមសីលធម៌ប្រពៃណីមួយ សម្រាប់ស្ត្រីកម្ពុជាគោរព ពីមួយជំនាន់ទៅមួយជំនាន់ ។

ប្តីដោយមិនបានសុំទោសប្តីជាមុនសិន ព្រមទាំងត្រូវអត់ធ្មត់ មិនត្រូវខឹងតបទេ ពេលដែលប្តីខឹងខ្លាំង។ វប្បធម៌ និង ប្រពៃណីបានបង្គាប់ស្ត្រីឱ្យប្រឹងប្រែងប្រតិបត្តិតាមឱ្យបាន នោះនឹងទទួលនូវភាពជោគជ័យ[៥] ។

## *វដ្តនៃអំពើហិង្សាក្នុងគ្រួសារ*

រឿងរ៉ាវរបស់ស្រីមុំ បង្ហាញនូវវដ្តនៃអំពើហិង្សាក្នុងគ្រួសារ និង ការកើតរឿងកាន់តែធំឡើងៗ។ អំពើហិង្សាក្នុងគ្រួសារជាធម្មតាតែងតែកើតមានម្តងហើយម្តងទៀតជាបន្តបន្ទាប់ឥតឈប់ឈរ។ វដ្តនៃអំពើហិង្សានេះជាធម្មតា មានបីដំណាក់កាល[៦] ។

**ភាពតានតឹង ឬ ការចាប់ផ្តើម (ដំណាក់កាលទី ១)**

កើនឡើងនូវភាពតានតឹង កំហឹង ការស្តីបន្ទោស និង ការឈ្លោះជជែកគ្នា។ អាចមានរហូតដល់មួយសប្តាហ៍ មួយខែ ឬ មួយឆ្នាំ។ វាកើតឡើងកាន់តែញឹកញាប់ឡើងៗជាវដ្តដដែលៗ។ ជាពិសេស ច្រើនតែមានការកើនឡើងនូវការឈ្លោះជជែកគ្នា និង ការរំលោភលើរាងកាយតិចតួច។

**ការរំលោភ (ដំណាក់កាលទី ២)**

ការរំលោភលើរាងកាយ ពាក្យសំដី ផ្លូវចិត្ត អារម្មណ៍ ផ្លូវភេទ។ ជនល្មើសបាត់បង់ នូវចេតនា ឬ លទ្ធភាពក្នុងការគ្រប់គ្រងកំហឹងរបស់ខ្លួនហើយចាប់ផ្តើមប្រើហិង្សា។

**ដំណាក់កាលស្ងៀមស្ងាត់ ឬ ធូរស្រាលឡើងវិញ (ដំណាក់កាលទី ៣)**

ដំណាក់កាលនេះ ជនល្មើសអាចមិនប្រព្រឹត្តហិង្សាទៀតទេ ដោយគិតថា ដោយសារតែខ្លួនស្រវឹង សុំទោស ហើយសន្យាថាឈប់ប្រព្រឹត្តទៀត។ ត្រង់ចំណុចកំពូលនៃដំណាក់កាលនេះ ភាគីទាំងពីរអាចបដិសេធ ឬ មួលបង្កាច់នូវអ្វីដែលបានកើតឡើង ។

វដ្តនៃអំពើហិង្សាក្នុងគ្រួសារអាចមើលឃើញនៅក្នុងរឿងរ៉ាវរបស់ស្រីមុំ ដែលប្តីរបស់នាង ឈ្មោះ សុខលី ចេះតែប្រើហិង្សាខ្លាំងឡើងៗចំពោះនាងអស់រយៈពេលជាច្រើនឆ្នាំ។ ជាដំបូង សុខលី ធ្វើបាបប្រពន្ធត្រឹមតែមានទំនាក់ទំនងជាមួយស្រីកំណាន់របស់ខ្លួន ហើយក្រោយមកក៏ចាប់ផ្តើមរំលោភដោយពាក្យសំដីមកលើស្រី មុំ។ អំពើហិង្សានេះ ក្រោយមកក៏ក្លាយទៅជាហិង្សាលើរាងកាយ ដោយសុខលីប្រើប្រាស់នូវអាវុធកាន់តែគ្រោះថ្នាក់ឡើងៗ

[៥] សូមមើលឯកសារ" អំពើហិង្សាលើស្ត្រីនៅកម្ពុជា (សរសេរដោយអ្នកស្រី ចូ អាន លីម លីកាដូ ខែមករា ឆ្នាំ២០០៦ ទំព័រ ៥ សម្រាប់ជាព័ត៌មានបន្ថែម)។

[៦] http://www.umass.edu/fsap/issues/violence.html

ជាលំដាប់ ដែលចាប់ផ្តើមពីដំបងឬស្សីនៅពេលដំបូង ហើយក្រោយមកឈានដល់ប្រើប្រាស់កាំបិត ហើយប្រើពូថៅចុងក្រោយ។ ជាចុងក្រោយ អំពើហិង្សាបានកើនឡើងកាន់តែខ្លាំងនៅ ពេលដែល សុខលីព្យាយាមសម្លាប់ស្រី មុំ។ នៅមុនពេលមានការកើនឡើងក្នុងដំណាក់កាលនីមួយៗនៃអំពើហិង្សាក៏មានដំណាក់កាលស្ងៀមស្ងាត់ ប៉ុន្តែរយៈពេលនេះកើតឡើងមិនសូវញឹកញាប់ទេ។ ចំណុចសំខាន់ត្រូវចងចាំថា ទោះបីជាមានអំពើហិង្សាបែបនេះក៏ដោយ ក៏ពុំបានបង្ខំស្រីមុំឱ្យទម្លាយនូវស្ថានភាពរបស់ខ្លួនទៅនរណាម្នាក់ដែលអាចជួយនាងបានឡើយ។ រហូតទាល់តែ សុខលី វាយលោភបំពានយ៉ាងហិង្សាលើកូនស្រី ទើប ស្រីមុំ ស្វះស្វែងរកគេជួយ ។

## *តើមានជំនួយអ្វីខ្លះសម្រាប់ស្រីមុំ?*

ស្រីមុំមិនដែលរកអ្នកណាជួយសោះអស់រយៈពេលជាច្រើនឆ្នាំ តាមពិតនាងអាចទៅរកអង្គការ នគរបាល ឬអាជ្ញាធរមូលដ្ឋាន ដូចជាមេភូមិ មេឃុំ ជាដើមឱ្យជួយ។ តាមច្បាប់ ស្រីមុំអាចប្តឹងប្តីនាង ពីបទព្រហ្មទណ្ឌ ដោយគាត់បានរំលោភ និង ប៉ុនប៉ងសម្លាប់នាង ហើយនាងអាចទាមទារសំណងរដ្ឋប្បវេណី ដើម្បីព្យាបាលរបួស និង/ឬប្តឹងសុំលែងលះគ្នា ។

ប៉ុន្តែចំពោះស្ត្រីស្ថិតក្នុងស្ថានភាពដូចជាស្រីមុំ ភាពខ្លាំង និង ឥទ្ធិពលច្បាប់ស្រី ស្លាកស្នាមជុំវិញអំពើហិង្សាក្នុងគ្រួសារ និង សេវាកម្មសង្គមនៅមានកំរិតទាបសម្រាប់ម្តាយមេម៉ាយនោះ ជាធម្មតាពុំបានលើកទឹកចិត្តឱ្យស្ត្រីស្វែងរកជម្រើសខាងលើនេះទេ។ លើសពីនេះទៅទៀត ជនរងគ្រោះដែលទៅរកនគរបាល ឬ អាជ្ញាធរមូលដ្ឋាន ឱ្យជួយនោះច្រើនតែពុំសូវទទួលបានការជួយជ្រុមជ្រែងប៉ុន្មានទេ។ ដោយសារតែជំនឿដ៏ទូលំទូលាយដែលជឿថា អំពើហិង្សាក្នុងគ្រួសារគឺជារឿងផ្ទៃក្នុង ត្រូវដោះស្រាយក្នុងរង្វង់គ្រួសារ អាជ្ញាធរជាធម្មតាច្រើនតែស្ទាក់ស្ទើរក្នុងកិច្ចអន្តរាគមន៍។ តាមពិត មនុស្សជាច្រើនយល់ឃើញថា អំពើដូចជា ការរំលោភបំពានលើរាងកាយ ឬរំលោភសេពសន្ថវៈ ពុំមែនជាបទឧក្រិដ្ឋទេ ប្រសិនបើកើតក្នុងរង្វង់គ្រួសារ។ ដូចនេះ គេច្រើនតែប្រាប់ជនរងគ្រោះឱ្យត្រឡប់ទៅវិញ ហើយពួកគេនឹងប្រឈមមុខនឹងអំពើហិង្សាថែមទៀត ។

## *ច្បាប់អំពើហិង្សាក្នុងគ្រួសារ*

ច្បាប់នេះត្រូវបានអនុម័តកាលពីថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៥ បានទុកជម្រើសជាច្រើនសម្រាប់ឱ្យជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារដូចជា ស្រី មុំ[៧] ជាជាងដាក់ការទទួលខុសត្រូវលើជនរងគ្រោះឱ្យនៅក្រោម

[៧] មាត្រា ៤-៥

ច្បាប់អំពើហិង្សាក្នុងគ្រួសារ គេបានកំណត់នូវភារកិច្ចមួយឱ្យអាជ្ញាធរទទួលខុសត្រូវក្នុងការអន្តរាគមន៍ករណីអំពើហិង្សាក្នុងគ្រួសារដែលគេបានដឹងដោយសកម្មភាពទាំងនោះរួមមាន:

- រឹបអូសអាវុធ ឬរបស់អ្វីដែលត្រូវបានប្រើ ឬអាចត្រូវបានប្រើដោយជនរងគ្រោះ។
- ជម្លៀសជនល្មើសចេញពីកន្លែងកើតហេតុ ឬ ជម្លៀសជនរងគ្រោះចេញពីកន្លែងកើតហេតុ។
- ជួយជនរងគ្រោះឱ្យបានសមរម្យ ស្របតាមកាលៈទេសៈជាក់ស្តែង ជាពិសេសផ្តល់កន្លែងស្នាក់នៅបណ្តោះអាសន្នដែលអាចធានាបាននូវសុវត្ថិភាព និង ការព្យាបាល ។

អាជ្ញាធរក៏ទទួលខុសត្រូវផងដែរ ឬ ជនរងគ្រោះដាក់ពាក្យទៅតុលាការ ដើម្បីឱ្យមានបញ្ជាការពារដែលអាចមានដូចខាងក្រោម:

- ហាមឃាត់ជនល្មើសមិនឱ្យប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារតទៀត
- ហាមឃាត់ជនល្មើសមិនឱ្យចូលជិត ឬ ចូលរួមរស់នៅក្នុងផ្ទះ ឬកន្លែងដែលជនរងគ្រោះកំពុងស្នាក់នៅ ឬ ធ្វើការងារ ។
- ហាមឃាត់ជនល្មើសមិនឱ្យទាក់ទងជនរងគ្រោះទោះជាតាមមធ្យោបាយណាក៏ដោយ
- ហាមជនល្មើសមិនឱ្យបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរួម ឬ ដាក់លក់ទ្រព្យសម្បត្តិរបស់ជនរងគ្រោះ ឬរបស់សាច់ញាតិជនរងគ្រោះ ។

ច្បាប់អំពើហិង្សាក្នុងគ្រួសារ បានដាក់កាតព្វកិច្ចឱ្យអាជ្ញាធរទទួលខុសត្រូវ(ឬអាជ្ញាធរនៅជិតបំផុត) ចាត់វិធានការបញ្ឈប់វិវឌ្ឍនៃអំពើហិង្សាឱ្យមានប្រសិទ្ធិភាព ដែលជាការទទួលខុសត្រូវរបស់សង្គម និង ពុំមែនត្រឹមតែជាការទទួលខុសត្រូវរបស់ជនរងគ្រោះក្នុងការបញ្ចេញមតិតែប៉ុណ្ណោះទេ។ ប៉ុន្តែបច្ចុប្បន្ន ច្បាប់នៅតែពុំទាន់ត្រូវបានប្រើប្រាស់ទូលំទូលាយនៅឡើយទេនៅកម្ពុជា ហេតុនេះហើយជនរងគ្រោះភាគច្រើននៅតែពុំទាន់ទទួលបានកិច្ចការពារនៅឡើយ។ កង្វះការអនុវត្តន៍ច្បាប់ដែលទំនងបណ្តាលមកពីឥរិយាបទធូរលុងក្នុងចំណោមសមាជិកអាជ្ញាធរនានាដែលយល់ថា អំពើហិង្សាក្នុងគ្រួសារពុំមែនជាបញ្ហាដែលគេគួរតែជ្រៀតជ្រែកទេ។ លើសពីនេះទៅទៀតធាតុពិតគឺច្បាប់អំពើហិង្សាក្នុងគ្រួសារពុំទាន់បានឱ្យនិយមន័យឱ្យបានច្បាស់នូវពាក្យដែលនិយាយថា "អាជ្ញាធរទទួលខុសត្រូវ" នេះគឺជាបញ្ហាមួយទៀត។ ផលប៉ះពាល់ជាធម្មតាគឺថា ការទទួលខុសត្រូវក្នុងកិច្ចការពារជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារត្រូវបានដាក់បន្ទុកទៅឱ្យមនុស្សដែលពុំបានកំណត់ ឬ អាចនិយាយជាសាមញ្ញថា គ្មានអ្នកណាទទួលខុសត្រូវទាល់តែសោះ។

រាជរដ្ឋាភិបាលគ្រាន់តែផ្តល់ការបំភ្លឺនៅក្នុងអនុក្រិត្យ និយមន័យនៃពាក្យថា អាជ្ញាធរជិតបំផុត និង អាជ្ញាធរទទួលខុសត្រូវដែលអាចធ្វើអន្តរាគមន៍ក្នុងកំឡុងពេលអំពើហិង្សាក្នុងគ្រួសារឡើងនោះជាការស្រេច។

បច្ចុប្បន្ននេះមានអនុក្រិត្យមួយកំពុងត្រូវបានគេព្រាងឡើង ប៉ុន្តែរហូតមកដល់ពេលនេះ អត្ថបទព្រាងនោះពុំទាន់ត្រូវបានផ្សព្វផ្សាយជាសាធារណនៅឡើយ ។

## ករណីអំពើហិង្សាក្នុងគ្រួសារដែលបានរាយការណ៍



រឿងរ៉ាវរបស់ស្រីមុំគឺជារឿងមួយដែលស្រដៀងទៅនឹងរឿងរ៉ាវរបស់ស្ត្រីរាប់ពាន់នាក់នៅកម្ពុជា[៨] ។ ក្នុងឆ្នាំ ២០០៦ មានស្ត្រី ២២០នាក់ បានមកកាន់អង្គការលីកាដូដើម្បីរាយការណ៍អំពីករណីរំលោភបំពានស្រដៀងគ្នា ដែលប្រព្រឹត្តដោយប្តីរបស់ពួកគាត់។ ជាធម្មតាស្ត្រីទាំងនេះបានចូល មកនៅក្រោយពេលដែលពួកគាត់រងគ្រោះដោយអំពើហិង្សា ក្នុងគ្រួសារជាច្រើនឆ្នាំរួចមកហើយ ដូចជាស្រីមុំជាដើម។

[៨] បណ្តឹងទទួលបានដោយអង្គការកម្ពុជា ៣ ដែលធ្វើការជាមួយជនរងគ្រោះដោយអំពើហិង្សាដែលផ្អែកទៅលើយេនឌ័រ - យោងតាមស្ថិតិរបស់លីកាដូ ពីឆ្នាំ ២០០០ - ២០០៦ សមាគមសិទ្ធិមនុស្ស និង អភិវឌ្ឍន៍កម្ពុជា ( អាដហុក ) -ស្ថិតិពីឆ្នាំ ២០០០ - ២០០៥ និងមជ្ឈមណ្ឌលកម្ពុជាដើម្បីស្ត្រីមានវិបត្តិ ស្ថិតិពីឆ្នាំ ១៩៩៧ ដល់ ២០០៥ ។

**ករណីអំពើហិង្សាក្នុងគ្រួសាររាយការណ៍ដោយ លីកាដូ ឆ្នាំ ២០០០-២០០៦**




របាយការណ៍ស្តីពីករណីអំពើហិង្សាក្នុងគ្រួសារដែលបានរាយការណ៍មកអង្គការលីកាដូ មានការកើនឡើងនៅក្នុងកំឡុងពេល ៣ឆ្នាំ កន្លងទៅនេះ។ ទោះបីជាវាតំណាងឱ្យការកើនឡើងពិត ឬមិនពិតក្នុងអំពើហិង្សាក្នុងគ្រួសារ ឬ ត្រឹមតែនៅក្នុងរបាយការណ៍នៃករណីអំពើហិង្សាក្នុងគ្រួសារក៏ដោយ ក៏នៅតែមិនដឹងច្បាស់ដែរ។ ប៉ុន្តែតាមការពិត អំពើហិង្សាក្នុងគ្រួសារជារឿងមួយធម្មតាជាទីបំផុតនៅកម្ពុជា ហេតុដូច្នេះចំនួនជនរងគ្រោះដ៏ច្រើនកំពុងស្វែងរកជំនួយ ។

## ការឆ្លើយតបរបស់រាជរដ្ឋាភិបាលចំពោះអំពើហិង្សាក្នុងគ្រួសារ[៩]

ក្រោមគោលដៅអភិវឌ្ឍន៏សហសវត្សកម្ពុជា រាជរដ្ឋាភិបាលប្តេជ្ញាកាត់បន្ថយអំពើហិង្សាលើស្ត្រី ដោយការតាក់តែង និង អនុវត្តផែនការទប់ស្កាត់ត្រឹមឆ្នាំ ២០០៥ ។

ក្នុងពេលកំពុងសរសេររបាយការណ៏នេះ ផែនការទប់ស្កាត់នេះពុំទាន់ត្រូវបានតាក់តែងចប់ និង អនុវត្តនៅឡើយទេ។ សេចក្តីព្រាងផែនការទប់ស្កាត់របស់ក្រសួងកិច្ចការនារីត្រូវបានដាក់ជូនក្រុមប្រឹក្សាពិគ្រោះយោបល់ផែន

[៩] ចំពោះព័តិមានបន្ថែមស្តីពីគោលនយោបាយរបស់រាជរដ្ឋាភិបាល បច្ចុប្បន្ន និង អតីតកាល សូមអានឯកសារអំពីហិង្សាលើស្ត្រីនៅកម្ពុជា (លីកាដូ ២០០៦ ) ទំ.៤

ការទប់ស្កាត់ចប់សព្វគ្រប់ (បង្កើតឡើងនៅខែវិច្ឆិកា ឆ្នាំ២០០៥) ដើម្បីជួយឱ្យផ្តល់យោបល់[១០] ។ តាំងពីពេលនោះមក ពុំទាន់ឃើញមានការរីកចម្រើនទៅមុខទៀតទេ ហើយផែនការទប់ស្កាត់នោះក៏ពុំទាន់ត្រូវបានឯកភាពយល់ព្រមដោយរាជរដ្ឋាភិបាលនៅឡើយដែរ ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលសម្រាប់ឆ្នាំ ២០០៦ -២០១០ ក៏បានគូសបញ្ជាក់នូវយុទ្ធសាស្ត្រមួយចំនួន ដើម្បីកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា។ ឧទាហរណ៍ តាមរយៈការផ្សព្វផ្សាយការយល់ដឹងស្តីពីចំណុចសំខាន់ៗ រាជរដ្ឋាភិបាលនឹង" ប្រយុទ្ធប្រឆាំងបញ្ហាអំពើហិង្សាក្នុងគ្រួសារដោយផ្ទាល់ និង បទដ្ឋានវប្បធម៌ដែលគាំទ្រអសមភាពយេនឌ័រយ៉ាងស្ទៀមស្វាត់នៅក្នុងចំណុចជាច្រើននៃសង្គម និង ជីវិតក្នុងគ្រួសារ"[១១] និង ដោះស្រាយនូវការផ្លាស់ប្តូរនយោបាយ និង ច្បាប់ដូចជា "អនុវត្តឱ្យបានហ្មត់ចត់ និង ពន្លឿននូវច្បាប់ដែលទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ និង អនុវត្តផែនការសកម្មភាពជាតិ ដើម្បីការពារជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ "។[១២] ប៉ុន្តែផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិខ្វះនូវវិធានការជាក់លាក់មួយចំនួន ដើម្បីអភិវឌ្ឍគោលបំណងទាំងនេះ ។

កាលពីថ្ងៃទី១៩ មករា ឆ្នាំ២០០៦នៅទីក្រុងញូយ៉ក គណកម្មាធិការ CEDAW នៃអង្គការសហប្រជាជាតិសម្ភាសន៍រាជរដ្ឋាភិបាលកម្ពុជាអំពីការអនុវត្តន៍ច្បាប់ CEDAW នេះនៅកម្ពុជា។[១៣] គណកម្មាធិការបានសួរតំណាងរាជរដ្ឋាភិបាលកម្ពុជាអំពីសុពលភាពនៃក្រមសីលធម៌ស្ត្រីដែលហៅថា "ច្បាប់ស្រី " ហើយបានសួរតើខ្លួនបានចាត់វិធានការដល់ដំណាក់ការណាហើយ ដើម្បីលុបបំបាត់ចោលនូវទំនៀមទម្លាប់ចាស់នេះ។ តំណាងរាជរដ្ឋាភិបាលកម្ពុជាបានឆ្លើយថា ក្រមសីលធម៌នោះ គឺជាបញ្ហាអត្តសញ្ញាណជាតិ ហេតុនេះ "ប្រសិនបើ នៅពេលដែលគោលការណ៍នេះត្រូវរត់បញ្ច្រាស់ទិសទៅនឹងតម្រូវការសង្គមបច្ចុប្បន្ន នោះវាអាចកែប្រែទំនៀមទំលាប់នោះបាននៅក្នុងដំណើរការមួយដែលពាក់ព័ន្ធជាមួយនឹងស្ថាប័នពាក់ព័ន្ធនានារួមទាំងសង្គមស៊ីវិលផងដែរ "។ ដូច្នេះ សមាជិកគណកម្មាធិការម្នាក់និយាយថា ខ្ញុំមិនយល់ "ថាតើគេអាចប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារបានដោយរបៀបណា បើពុំមានការលុបបំបាត់នូវច្បាប់ស្រីនោះ ច្បាប់នោះគឺជាផ្នែកមួយដែលបានធ្វើឱ្យស្ត្រីស្ថិតនៅក្នុងភាពអន់ថយ និង នៅក្រោមគេជានិច្ច។ ច្បាប់នេះក៏បានផ្តល់អំណាចឱ្យបុរសប្រៀនប្រដៅស្ត្រីណាដែលមិនគោរពប្តីផងដែរ"។ តំណាងរាជរដ្ឋាភិបាលកម្ពុជាពុំមានចម្លើយតបវិញទៅនឹងយោបល់នេះទេ។

---

[១០] ធ្វើបទបង្ហាញដោយ លោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី (ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍កម្ពុជា ថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០០៦ )។ httpp:/www.cdc-crdb.gov.kh/cdc/gdce/eight_women_affairs.html

[១១] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៦ - ២០១០ ទំ. ៧៥ ។

[១២] ឯកសារដូចខាងលើ។

[១៣] គណកម្មាធិការប្រឆាំងការរើសអើងស្ត្រីពិចារណាលើរបាយការណ៍កម្ពុជា : "ក្រមសីលធម៌" អំពើជួញដូរ កូតា ក្នុងចំណោមបញ្ហាទាំងឡាយដែល បានដោះស្រាយ (គណកម្មាធិការប្រឆាំងនឹងការរើសអើងស្ត្រី អង្គការសហប្រជាជាតិ - កិច្ចប្រជុំលើកទី ៧០៥ និង ៧០៦ នៅថ្ងៃទី ១៩ មករា ឆ្នាំ ២០០៦)។ http://www.un.org/News/Press/docs/2006/wom1530.doc.htm

# ៣. អំពើរំលោភសេពសន្ថវៈ

**ក្នុងជំពូកនេះ...**

**ករណីសិក្សា ២: រំលោភសេពសន្ថវៈ បញ្ហារំលោភសេពសន្ថវៈ : រឿងរ៉ាវរបស់ លី វីដែន**

- *តរិយាបទសង្គម និង វប្បធម៌កម្ពុជា*
- *ភស្តុតាងវេជ្ជសាស្ត្រនៃអំពើរំលោភសេពសន្ថវៈ*
- *និទ្ទណ្ឌភាព*
- *ការសងសំណងរដ្ឋប្បវេណីខុសច្បាប់*
- *បញ្ហាធ្ងន់ធ្ងរផ្សេងទៀត*

**ករណីរំលោភសេពសន្ថវៈដែលបានរាយការណ៍**

- *ពុំមានរបាយការណ៍*

**ករណីសិក្សា ៣ : ការរំលោភជាពួក**

**បញ្ហារំលោភសេពសន្ថវៈជាពួក : រឿងរបស់ដេត**

- *ភាពទន្ទត់ និង អាម៉ាស់*
- *ទម្រង់នៃអំពើរំលោភសេពសន្ថវៈ និង តរិយាបទដែលជុំរុញឱ្យមាន*

**ករណីរំលោភសេពសន្ថវៈជាពួកដែលបានរាយការណ៍**

**ការឆ្លើយតបរបស់រាជរដ្ឋាភិបាលចំពោះអំពើរំលោភសេពសន្ថវៈ**

អំពើរំលោភសេពសន្ថវៈគឺ ជាបទឧក្រិដ្ឋតាមច្បាប់ព្រហ្មទណ្ឌអ៊ុនតាក់[១៤] ហើយតាមច្បាប់ស្តីពីស្ថានទម្ងន់ ទោសព្រហ្មទណ្ឌ[១៥]។ និយមន័យនៃពាក្យរំលោភគឺ "រាល់អំពើផ្លូវភេទណាដែលពាក់ព័ន្ធនឹងការប្រព្រឹត្ត ដោយរំលោភបំពាន សាហាវ បង្ខំ ឬ ធ្វើឱ្យមាន ការភ្ញាក់ផ្អើល"[១៦]។ ការប្រព្រឹត្តអំពើរំលោភសេព សន្ថវៈ ឬការប៉ុនប៉ងរំលោភក៏ត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋដូចគ្នាដែរតាមច្បាប់កម្ពុជា។[១៧]

**ករណីសិក្សា ២ : រំលោភសេពសន្ថវៈ**

*ខ្ញុំឈ្មោះ លី វីដែន អាយុ ១៨ឆ្នាំ។ ខ្ញុំត្រូវបានគេចាប់រំលោភសេពសន្ថវៈ ហើយខាងក្រោមនេះគឺ ជារឿងរ៉ាវរបស់ខ្ញុំ។*

*ខ្ញុំរស់នៅជាមួយម្តាយមីង និងបងស្រីខ្ញុំនៅក្នុងភូមិមួយ។ យើងទាំងអស់គ្នាជាកសិករធ្វើការនៅក្នុងចម្ការ និង វាលស្រែ ។*

*ថ្ងៃមួយបងស្រីខ្ញុំ និង ខ្ញុំបានទៅឃ្វាលគោនៅតាមវាលស្រែក្បែរៗភូមិ។*

---

[១៤] ច្បាប់ព្រហ្មទណ្ឌអ៊ុនតាក់ មាត្រា ៣៣ ។

[១៥] ច្បាប់ស្តីពីស្ថានទម្ងន់ទោសព្រហ្មទណ្ឌ មាត្រា ៥ ។

[១៦] ច្បាប់ព្រហ្មទណ្ឌអ៊ុនតាក់ មាត្រា ៣៣ និង ច្បាប់ស្តីពីស្ថានទម្ងន់ទោសព្រហ្មទណ្ឌ មាត្រា ៥ ។

[១៧] ច្បាប់ស្តីពីស្ថានទម្ងន់ទោសព្រហ្មទណ្ឌ មាត្រា ៥។

យើងបានឱ្យគោដើរស៊ីស្មៅតាមវាលស្រែនានាហើយយើងនាំគ្នាទៅសម្រាកនៅពេលដែលគោកំពុងស៊ីស្មៅ ។ បងស្រីខ្ញុំពីរនាក់នាំគ្នាទៅហែលទឹកនៅក្នុងស្រះទឹកមួយជិតនោះ រីឯបងស្រីម្នាក់ទៀត និងខ្ញុំបានទៅអង្គុយនៅក្រោមដើមឈើមួយដើម្បីមើលគោ នឹងជជែកគ្នាលេង ។

ប្រហែលជាកន្លះម៉ោងក្រោយមក បុរសម្នាក់ដែលខ្ញុំមិនដែលស្គាល់សោះ បានដើរមកជិតខ្ញុំ ហើយសួរខ្ញុំថា មានឃើញមេគោគាត់ ៤ ក្បាលដើរមកជិតៗនេះដែរឬទេ? ខ្ញុំបានប្រាប់បុរសនោះថា ខ្ញុំអត់បានឃើញទេ ចូរពូទៅរកនៅឯវាលស្រែទៅ ។ បុរសនោះនៅតែឈរជិតខ្ញុំតទៅទៀត បន្តជជែកជាមួយខ្ញុំ - គាត់ហាក់ដូចជាចាប់អារម្មណ៍ចំពោះខ្ញុំខ្លាំងណាស់ ។

បងស្រីខ្ញុំពីរនាក់ទៀត ដែលកំពុងហែលទឹកក្នុងស្រះ បានស្រែកហៅពួកយើង ហើយឱ្យពួកខ្ញុំម្នាក់យកក្រមាមួយឱ្យគាត់ ។ ខ្ញុំបានឱ្យប្អូនស្រីខ្ញុំយកទៅ ដោយជាប់និយាយជាមួយបុរសនោះ ។ ខ្ញុំបានឃើញប្អូនស្រីដើរទៅឆ្ងាយ ។ ពេលដែលវាបានទៅដល់ស្រះទឹក បុរសនោះងាកមកចាប់ខ្ញុំឱបរឹតបឺយកទៅប្រឡាយទឹកជិតនោះ ។ ខ្ញុំខំប្រឹងស្រែកឱ្យគេជួយ ប៉ុន្តែគាត់ខ្ទប់មាត់ជាប់ ហើយគាត់មិនលែងខ្ញុំទេ ។ ខ្ញុំនៅតែប្រឹងរើបំរះដើម្បីរត់គេចចេញ ប៉ុន្តែខ្ញុំរើមិនរួចពីគាត់សោះ ។ ខ្ញុំមានការភ័យខ្លាចជាខ្លាំង ។ ខ្ញុំបានប្រឹងរើគេចឱ្យរួច ប៉ុន្តែទីបំផុត -បុរសនោះនៅតែរំលោភខ្ញុំបាន ។

ក្រោយពីរំលោភរួចហើយ បុរសនោះរត់ទៅបាត់ ។ ខ្ញុំខំប្រឹងក្រោកឡើង ហើយដើរទៅរកបងស្រីខ្ញុំ ។ ខ្ញុំគិតថា ខ្ញុំត្រូវតែស្រែក ធ្វើបែបនេះបងស្រីខ្ញុំនឹងរត់មករកខ្ញុំ ។ ពួកគេចេះតែសួរខ្ញុំថា មានរឿងអ្វី? ខ្ញុំមិនប្រាប់ពួកគាត់ទេ ដោយមានការអាម៉ាស់ជាខ្លាំង ។

ក្រោយមកពួកគាត់បានសែងខ្ញុំទៅផ្ទះ ហើយខ្ញុំបានប្រាប់មីងខ្ញុំនូវរឿងដែលបានកើតឡើង ។ មីងខ្ញុំខឹងនឹងបុរសនោះជាខ្លាំង ហើយក៏ទៅប៉ុស្តិ៍នគរបាលភ្លាម ដើម្បីរាយការណ៍ពីរឿងនេះ ។ បងស្រីខ្ញុំ នាំខ្ញុំទៅងូតទឹក ហើយចូលដេក ប៉ុន្តែ ខ្ញុំដេកមិនលក់ទេ ។ ខ្ញុំខ្លាចណាស់ពេលដែលខ្ញុំនៅតែម្នាក់ឯង ក្រោយមកប្អូនស្រីខ្ញុំក៏ចូលមកដេកជាមួយ ។

មួយថ្ងៃក្រោយមក នគរបាលក៏ចាប់បុរសនោះបានហើយបញ្ជូនទៅពន្ធនាគារ ។ ពេលនោះ ខ្ញុំដូចជាមានអារម្មណ៍លែងសូវខ្លាចដូចពេលមុនទៀត ដោយបានឮថាគាត់នោះចូលពន្ធនាគារ ហើយមិនអាចធ្វើអ្វីខ្ញុំទៀតទេ ហើយខ្ញុំក៏លែងឃើញគាត់ទៀតដែរ ។ ប៉ុន្តែ ខ្ញុំនៅតែដេកមិនលក់ដដែល ហើយចាប់ពីពេលនោះមក ខ្ញុំលែងទៅណាតែម្នាក់ឯងទៀតហើយ ។

*ពីរ-បីអាទិត្យក្រោយពីបុរសនោះចូលពន្ធនាគារ នគរបាល និងបុរសចម្លែកម្នាក់បានមកជួបមីងខ្ញុំ។ ខ្ញុំមិនដឹងថា មូលហេតុអ្វីបានជាគេមកសួរមីងខ្ញុំទេ។ បន្ទាប់ពីបុរសទាំងពីរនោះចេញទៅវិញ មីងខ្ញុំប្រាប់ខ្ញុំថា នគរបាល បានមកជាមួយនឹងឪពុកបុរសដែលរំលោភខ្ញុំ។ បុរសនោះបាននិយាយពីរឿងបង់លុយកាក់ដែលកូនគាត់បានរំលោភខ្ញុំ។ ប៉ុន្តែគាត់ថា បើយើងមិនប្តឹងកូនគាត់ នោះទើបគាត់ព្រមបង់លុយ។*

*ខ្ញុំមិនយល់សាច់រឿងនេះយ៉ាងម៉េចទេ ហើយមីងខ្ញុំប្រាប់ខ្ញុំថា បើយើងយកលុយនោះវាល្អជាងដោយគេបង់លុយឱ្យច្រើនដែរ រហូតដល់ ៤ លានរៀល ស្មើនឹង ១.០០០ ដុល្លារ។ ខ្ញុំស្តាប់តាមមីងហើយគាត់និយាយជាមួយនគរបាល។ ក្រោយមក បុរសនោះត្រូវបានដោះលែងពីពន្ធនាគារ ហើយខ្ញុំក៏មិនបានឃើញគាត់ដែរតាំងពីពេលនោះមក។ នគរបាលក៏យកលុយសំណងនោះឱ្យមីងខ្ញុំ ពួកខ្ញុំទទួលបានត្រឹមតែ ៧០០ ដុល្លារប៉ុណ្ណោះ។ មីងខ្ញុំនិយាយថា នគរបាលដកយកលុយខ្លះ ដើម្បីជាថ្លៃជួយក្នុងការរត់ការដោះស្រាយ។*

*ខ្ញុំនៅតែមានអារម្មណ៍សោកស្តាយ និងខឹងយ៉ាងខ្លាំងនូវរឿងដែលបានកើតឡើងចំពោះខ្ញុំ។ ខ្ញុំមិនយល់អំពីបញ្ហារឿងលុយដែលបង់ឱ្យនោះទេ។ ជាមួយនឹងលុយនេះ វាអាចជួយឱ្យប្អូនស្រីខ្ញុំបានទៅរៀនហើយខ្ញុំអាចឱ្យមីងខ្ញុំខ្លះ ដើម្បីជួយគាត់។ ប៉ុន្តែខ្ញុំ គិតថាប្រសិនបើបុរសនោះជាប់ពន្ធនាគារ នោះខ្ញុំដូចជាមានអារម្មណ៍ស្ងប់ជាង ដោយខ្ញុំមិនភ័យខ្លាចគាត់ទៀត ។*

## បញ្ហារំលោភសេពសន្ថវៈ : រឿងរ៉ាវរបស់ លី វីដែន

### ***ឥរិយាបថសង្គម និង វប្បធម៌កម្ពុជា***

ច្បាស់ណាស់នៅក្នុងករណីរបស់ លី វីដែន ដែលនាងមានការអាម៉ាស់នូវអ្វីដែលបានកើតឡើងចំពោះនាង ហើយនេះអាចមើលឃើញនូវការឆ្លើយតបរបស់នាងចំពោះប្អូនស្រីនាង។ ពេលដែលគេសួរនាង ដំបូងអំពីព័ត៌មាន នាងបានបដិសេធមិនឆ្លើយទេ។ អំពើរំលោភសេពសន្ថវៈត្រូវពិនិត្យមើលនៅក្នុងបរិបទនៃឥរិយាបថវប្បធម៌ និង សង្គមកម្ពុជា ស្តីពីការរួមភេទរវាងបុរស និង ស្ត្រី ។

នៅក្នុងសង្គមកម្ពុជា បុរសហាក់ដូចជាមានតម្លៃខ្ពស់ជាងស្ត្រី។[១៨] ពាក្យបុរាណខ្មែរមួយនិយាយថា "បុរសចាត់ទុកដូចជា មាសទឹកដប់ ហើយស្ត្រីដូចជាសំពត់ស"។ ពាក្យពីបុរាណជាការបង្ហាញនូវបទដ្ឋានត្រួតគ្នាមួយនៅកម្ពុជា ដែលបុរសអាចមានការប្រឡូកប្រឡាក់ ហើយមិនចេះស្រអ័ព្វទៀត ដោយមាសនៅតែស្អាតដដែលក្រោយពីលាងទឹកហើយ។ ប៉ុន្តែស្ត្រីវិញ ពេលដែលនាងបាត់បង់ព្រហ្មចារីហើយ នោះប្រៀបដូចជាសំពត់សដែលប្រឡាក់ភក់មិនអាចលាងសំអាតឱ្យស្អាតវិញបានទេ។[១៩]

ស្ត្រីកម្ពុជាត្រូវតែរក្សាព្រហ្មចារីរបស់ខ្លួនឱ្យបានរហូតដល់ពេលរៀបការ បើពុំដូច្នេះទេ ពុំមានបុរសណារៀបការជាមួយនាងទេ ទោះបីជានាងបាត់បង់ព្រហ្មចារីដោយសារគេរំលោភក៏ដោយ។[២០] ហើយការបាត់បង់នូវព្រហ្មចារីគឺពុំមែនជាកំហុសរបស់ពួកគេទេ។ ជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈជាច្រើន បានលាក់បាំងដោយសារតែភាពអាម៉ាស់ ឬ ត្រូវគេស្តីបន្ទោស ឬ នាងអាចដាក់កំហុសខ្លួនឯងដែលបណ្តាលឱ្យមានបញ្ហានេះ។

អ្នកដែលបានរស់រានមានជីវិតដោយសារអំពើរំលោភសេពសន្ថវៈ ច្រើនតែប្រឈមមុខនឹងតិរិយាបទរើសអើងពីសង្គមដែលចាត់ទុកនាងថាជាស្រីខូច។ ការឈប់រាប់រកពីសំណាក់សង្គម និង ភាពអាម៉ាស់របស់គ្រួសារដោយសារតែការបាត់បង់ព្រហ្មចារីនៅពេលដែលត្រូវគេរំលោភនោះ គឺជាកត្តាសំខាន់មួយដែលដក់ជាប់នៅក្នុងអារម្មណ៍ស្ត្រីរងគ្រោះមួយចំនួន ហើយគិតថាមុខជំនាញតែមួយគត់របស់ពួកគេគឺស្ត្រីរកស៊ីផ្លូវភេទ។ អាចមានឪពុក-ម្តាយខ្លះជំរុញឱ្យកូនចូលទៅរកស៊ីបម្រើផ្លូវភេទផង ប្រសិនបើ កូនស្រីពួកគេអស់ព្រហ្មចារីហើយ។ ក្នុងករណីខ្លះទៀត ជនរងគ្រោះត្រូវបានបង្ខំឱ្យរៀបការជាមួយជនល្មើសដែលរំលោភខ្លួន ដែលជាការជួយស្រោចស្រង់កេរ្តិ៍ឈ្មោះគ្រួសារ។[២១]

[១៨] រំលោភ និង បៀតបៀនកេរ្តិ៍ខ្មាស : របាយការណ៍បទឧក្រិដ្ឋក្នុងសហគមន៍ (ដៀន អូ ខូណែល របាយការណ៍ពិសេស លីកាដូ ខែ កុម្ភៈ ឆ្នាំ ២០០១ ទំព័រ ១០ - របាយការណ៍អង្គការមិនមែនរដ្ឋាភិបាលកម្ពុជាស្តីពីការអនុវត្តន៍វេទិកាការប៉េកាំង ដើម្បីសកម្មភាព ចងក្រងដោយក្រុមការងារប៉េកាំង ៥ នៃបណ្តាញអភិវឌ្ឍន៍ និង យេនឌ័រ និង វេទិការអង្គការមិនមែនរដ្ឋាភិបាលនៃក្រុមការងារស្ត្រី ខែកុម្ភៈ ឆ្នាំ២000) ទំព័រ ២១ ។

[១៩] ឯកសារដូចខាងលើ ទំព័រ ១០ ។ គ្រូពេទ្យសិទ្ធិមនុស្ស ១៩៩៦ អាជីវកម្មផ្លូវភេទនៃស្ត្រី និង កុមារនៅកម្ពុជា (ការពិពណ៌នាផ្ទាល់ខ្លួន : ទស្សនៈចិត្តសាស្ត្រ -បូស្តុន ១៩៩៧) ។

[២០] OP Cit 10 P.10 បញ្ជាក់អំពីកុមារ និង យុវជនដែលត្រូវគេធ្វើអាជីវកម្មផ្លូវភេទ និង រំលោភផ្លូវភេទនៅកម្ពុជា — ការវាយតម្លៃទៅលើតម្រូវការផ្នែកសុខភាព និង សេវាកម្មដែលមានស្រាប់មួយចំនួន ។ (អង្គការសហប្រជាជាតិ -គណកម្មាធិការសង្គមសម្រាប់អាស៊ី និង ប៉ាស៊ីហ្វិក ញូវយ៉ក ឆ្នាំ២000) ។

[២១] Op Cit 18, P.i.

## ភស្តុតាងវេជ្ជសាស្ត្រនៃអំពើរំលោភសេពសន្ថវៈ

ក្រោយពីនាងត្រូវរំលោភបងស្រីរបស់ លី វីដែន បាននាំនាងទៅផ្ទះ ហើយបានប្រាប់ឱ្យនាងលាងសំអាតខ្លួនចេញ។ ស្ត្រីកម្ពុជា ជាច្រើននៅមិនទាន់យល់ថា វាសំខាន់ទេ ការទៅជួបវេជ្ជបណ្ឌិត ក្រោយពេលរំលោភផ្លូវភេទរួច ដើម្បីប្រមូលភស្តុតាងចងក្រងជាឯកសារមុននឹងលាងសំអាតខ្លួន។ ប៉ុន្តែ ភស្តុតាងនេះពុំត្រូវគិតថាជាភស្តុតាង តែមួយគត់ក្នុងការកំណត់ថាបទល្មើសរំលោភសេពសន្ថវៈបានកើតឡើង ឬ អត់នោះទេ នៅក្នុងករណីរំលោភសេពសន្ថវៈជាច្រើន ចៅក្រមច្រើនតែពឹងផ្អែកទៅលើភស្តុតាងវេជ្ជសាស្ត្រ ដើម្បីផ្តន្ទាទោសជនល្មើស។ ប្រសិនបើគ្មានភស្តុតាងលើរាងកាយនិងគ្មានលិខិតកោសល្យវិច្ឆ័យបញ្ជាក់ថាមានការរំលោភទេ នោះចៅក្រមអាចប្រកាស ថាជាការរួមភេទដោយមានការព្រមព្រៀងគ្នាពុំមែនជាករណីរំលោភសេពសន្ថវៈទេ ។[២២]

## និទ្ទណ្ឌភាព

ករណីរបស់ លី វីដែន ជាដំបូងជនល្មើសត្រូវបានឃុំខ្លួន ប៉ុន្តែ ក្រោយមកគាត់សូកលុយដើម្បីឱ្យមានសេរីភាពឡើងវិញ ហើយថែមទាំងអាចបង្ខំវីដែនឱ្យដកពាក្យបណ្តឹងវិញផង។ វប្បធម៌និទ្ទណ្ឌភាពបានកើតឡើងចំពោះជនល្មើសនៃអំពើរំលោភសេពសន្ថវៈដែលជាបទឧក្រិដ្ឋនៅកម្ពុជា។ ជនល្មើសប្រព្រឹត្តរំលោភសេពសន្ថវៈជាច្រើនបានជឿថា ពួកគេស្ថិតនៅពីលើច្បាប់ ហេតុនេះ បើសិនជាត្រូវបានចាប់ខ្លួននោះ ទណ្ឌកម្មតែមួយគត់គឺបង់លុយ។ គួរឱ្យសោកស្តាយទៀតនោះគឺ ឥរិយាបទសង្គម និង វប្បធម៌កម្ពុជា រួមជាមួយនឹងភាពក្រីក្រតោកយ៉ាក ទីបំផុតជាធម្មតាគេបង្ខំឱ្យជនរងគ្រោះ ដោយអំពើរំលោភសេពសន្ថវៈពាក់ព័ន្ធទៅនឹងវប្បធម៌និទ្ទណ្ឌភាព ដែលជនល្មើសបានប្រព្រឹត្តបទល្មើសរំលោភនេះចំពោះខ្លួន។



## ការសងសំណងរដ្ឋប្បវេណីខុសច្បាប់

ឧបសគ្គមួយដ៏ធំក្នុងការផ្តន្ទាទោសជនល្មើសក្នុងករណីរំលោភសេពសន្ថវៈគឺ ការអនុវត្តន៍ផ្ទុយនឹងច្បាប់ ដោយការសងសំណងរដ្ឋប្បវេណី។ ការសងជម្ងឺចិត្តបែបនេះជាការដោះស្រាយមានប្រសិទ្ធិភាពខ្លាំងនៅខាងក្រៅតុលាការ រវាងជនរងគ្រោះ និង ជនល្មើស(ឬគ្រួសាររបស់ពួកគេ)។ ជាលទ្ធផល ជនល្មើសបង់លុយឱ្យទៅជនរងគ្រោះ ដើម្បីកុំឱ្យប្តឹងទៅតុលាការ។ ជនល្មើសអាចសូកលុយ ដើម្បីគេចផុតពីការផ្តន្ទាទោស។ ជនល្មើសដែល

[២២] រំលោភ និង បៀតបៀនកេរ្តិ៍ខ្មាស (របាយការណ៍លីកាដូ ខែ មីនា ២០០៤)ទំ. ១៣ ។

រំលោភ វីដែន អាចសូកលុយឱ្យរួចខ្លួនពីពន្ធនាគារបានយ៉ាងមានប្រសិទ្ធិភាព ហើយការដោះស្រាយសងសំណង រដ្ឋប្បវេណីខុសច្បាប់របស់សាច់ញាត្តិជនល្មើស ត្រូវបានរត់ការដោះដោយនគរបាល។ នៅក្នុងករណីមួយចំនួន នគរបាលអាចជួយបង្ខំឱ្យជនរងគ្រោះដោះស្រាយជាមួយនឹងជនល្មើស ទង្វើបែបនេះពួកគេអាចទទួលបានកម្រៃខ្លះៗក្នុងការជួយរត់ការរកដំណោះស្រាយនេះ។ ក្នុងករណីរបស់ វីដែន នគរបាល ទទួលបានកម្រៃជើងសារ។ ភាគច្រើនគ្រួសាររបស់ជនរងគ្រោះគិតថា ពួកគេគ្មានជម្រើសទេ ពីព្រោះពួកគេស្ថិតនៅក្នុងស្ថានភាពមួយដែលងាយរងគ្រោះ ក្រីក្រ និង គ្មានបក្សពួក ហើយពួកគេទទួលរងការគំរាមកំហែង ឬ បំភិតបំភ័យដោយអាជ្ញាធរ ឬ គ្រួសាររបស់ជនជាប់ចោទ។[២៣] ស្ថានភាពរបស់វីដែនមិនខុសពីស្ថានភាពដូចបានរៀបរាប់នេះទេ ដោយម្តាយមីងរបស់ នាងក្រីក្រជាខ្លាំង ហើយគ្រួសាររបស់នាងត្រូវការប្រាក់។

ក្រោមច្បាប់កម្ពុជា ជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈ ត្រូវបានអនុញ្ញាតឱ្យប្តឹងបណ្តឹងពីរប្រភេទ បណ្តឹងព្រហ្មទណ្ឌ និង បណ្តឹងរដ្ឋប្បវេណី។ បណ្តឹងរដ្ឋប្បវេណីនេះ ជាបណ្តឹងដែលបង្ខំឱ្យជនល្មើសសងសំណងរដ្ឋប្បវេណីទៅជនរងគ្រោះ។ ប៉ុន្តែការសងសំណងរដ្ឋប្បវេណីដែលជាលទ្ធផលនៃបណ្តឹងនេះ ពុំមែនមានន័យថាជនរងគ្រោះអស់សិទ្ធិប្តឹងជនល្មើសនូវបណ្តឹងព្រហ្មទណ្ឌទេ។

វាអាចជាការលំបាកណាស់សម្រាប់ជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈ ក្នុងការយល់នូវបញ្ហានេះ ដោយសារតែការដោះស្រាយខុសច្បាប់បែបនេះហើយ ទើបមានការកើនឡើងជាទូទៅនៅកម្ពុជា ហើយនៅក្នុងករណីជាច្រើនទៀត ការដោះស្រាយបែបនេះត្រូវផ្តួចផ្តើមដោយនគរបាល និង អាជ្ញាធរពាក់ព័ន្ធនានា។ ប៉ុន្តែ ការដោះស្រាយខុសច្បាប់នេះពុំបានជួយស្រោចស្រង់ស្ថានភាពពីការផ្តន្ទាទោសជនល្មើសទេ ជាក់ស្តែងទៅវាជាអំពើខុសច្បាប់ក្នុងការបញ្ចប់ករណីព្រហ្មទណ្ឌ ដោយកិច្ចព្រមព្រៀងសងសំណងរដ្ឋប្បវេណីជាលក្ខណៈឯកជនបែបនេះ។[២៤]

## *បញ្ហាធ្ងន់ធ្ងរផ្សេងទៀត*

មានបញ្ហាសំខាន់ៗច្រើនអនេកពាក់ព័ន្ធទៅនឹងអំពើរំលោភសេពសន្ថវៈ ច្បាប់ និង ដំណើរការតុលាការនៅកម្ពុជា។ ទាញចេញពីទស្សនៈរបស់ជនរងគ្រោះ វាហាក់ដូចជាមានឧបសគ្គយ៉ាងច្រើនដែលមិនអាចយកជ័យជំនះបានក្នុងការព្យាយាមបន្តជីវិតរបស់ខ្លួន និង ក្នុងការព្យាយាមរកជំនួយដើម្បីទទួលបានសំណងរដ្ឋប្បវេណី និង ឈានទៅដល់ការផ្តន្ទាទោសជនល្មើស ។ ឧទាហរណ៍មួយចំនួនរួមមានៈ[២៥]

- ការបកស្រាយច្បាប់ខុសដោយចៅក្រម ព្រះរាជអាជ្ញា និង មេធាវីការពារក្តី

[២៣] Op Cit 18, p.51.

[២៤] មាត្រា ៧ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។

[២៥] សូមអានរបាយការណ៍ចាស់របស់លីកាដូ ស្តីពីហិង្សាលើស្ត្រី (ខែ មករា ឆ្នាំ ២០០៦) ដើម្បីជាព័ត៌មានបន្ថែម ។

- អំពើពុករលួយ
- ពុំមានមាត្រាចែងអំពីរំលោភគ្រប់គ្រាន់នៅក្នុងច្បាប់

## ករណីរំលោភសេពសន្ថវៈដែលបានរាយការណ៍

ក្នុងឆ្នាំ ២០០៦ លី វីដែន គឺជាស្ត្រីម្នាក់ក្នុងចំណោមស្ត្រីទាំង ៨៦ នាក់ ដែលត្រូវរាយការណ៍ថា នាងត្រូវបានរំលោភ ហើយមករាយការណ៍ដល់អង្គការលីកាដូ ។

**ករណីរំលោភសេពសន្ថវៈរាយការណ៍ដោយ លីកាដូ ពីឆ្នាំ ២០០០-២០០៦**




ចន្លោះពីឆ្នាំ ២០០៥-២០០៦ មានការកើនឡើងយ៉ាងខ្លាំងនូវចំនួនករណីរំលោភសេពសន្ថវៈដែលរាយការណ៍មកអង្គការលីកាដូ មានការកើនឡើងជាង ២០ ភាគរយក្នុងមួយឆ្នាំ។ ក៏ដូចអំពើហិង្សាក្នុងគ្រួសារផងដែរ ជាការលំបាកណាស់ក្នុងការរកមូលហេតុនៅពីក្រោយការកើនឡើងនេះ និង ដើម្បីកំណត់ថា តើមានករណីរំលោភសេពសន្ថវៈច្រើនទៀតកើតឡើងមែនឬទេ ឬតើស្ត្រីភាគច្រើនមានការយល់ដឹងអំពីសិទ្ធិរបស់ខ្លួនដែរឬទេ និងមានឆន្ទៈក៏ដូចជាហ៊ានរាយការណ៍នូវបទល្មើសសេពសន្ថវៈនេះដែរឬទេ ។

អង្គការលីកាដូក៏ធ្វើការស៊ើបអង្កេតករណីរំលោភសេពសន្ថវៈដែលរាយការណ៍នៅក្នុងកាសែតកម្ពុជា និង កាសែតបរទេស រួមទាំងប្រព័ន្ធឃោសនាផ្សេងៗទៀតដែរ[២៦] ។ ជាថ្មីម្តងទៀត ការរាយការណ៍បទល្មើសរំលោភសេពសន្ថវៈបានកើនឡើងនៅក្នុងប៉ុន្មានឆ្នាំកន្លងទៅនេះ ។

**ចំនួនករណីរំលោភសេពសន្ថវៈដកស្រង់ពីប្រព័ន្ធផ្សព្វផ្សាយពីឆ្នាំ ២០០៤-២០០៦**




***ពុំមានរបាយការណ៍***[២៧]

បទល្មើសរំលោភសេពសន្ថវៈគឺ ជាបទល្មើសមួយប្រភេទដែលភាគច្រើនមិនត្រូវបានរាយការណ៍នៅកម្ពុជា អាស្រ័យដោយកត្តាជាច្រើន រួមមានភាពអាម៉ាស់ ឬ ការយល់ឃើញថាជាកំហុសរបស់ខ្លួនឯង ដែលបណ្តាលឱ្យមានអំពើនេះកើតឡើង ការមិនជឿជាក់លើប្រព័ន្ធច្បាប់ និង តុលាការដោយសារតែអំពើពុករលួយ និងការដោះស្រាយសងសំណងរដ្ឋប្បវេណីក្រៅប្រព័ន្ធតុលាការ ។

[២៦] សារព័ត៌មានដែលត្រូវបានឃ្លាំមើលមានរស្មីកម្ពុជា កម្ពុជាថ្មី កោះសន្តិភាព និង Cambodia Daily

[២៧] ចំពោះទស្សនៈទូទៅនៃករណីរំលោភសេពសន្ថវៈមិនបានរាយការណ៍ សូមអាន ឯកសារអំពីហិង្សាលើស្ត្រីនៅកម្ពុជា (លីកាដូ ខែមករា ឆ្នាំ២០០៦) ទំ. ៨ ។

## ករណីសិក្សា ៣ : ការរំលោភសេពសន្ថវៈជាពួក

ខ្ញុំឈ្មោះ ដេត អាយុ ២៤ឆ្នាំ។ ខ្ញុំត្រូវបានបុរស ៨ នាក់ចាប់បង្ខំរំលោភ ហើយខាងក្រោមនេះគឺជារឿងខ្ញុំផ្ទាល់។

ខ្ញុំរស់នៅជាមួយឪពុកម្ដាយ បងប្អូនប្រុសស្រី។ រៀងរាល់ថ្ងៃខ្ញុំជួយលក់ដូរអីវ៉ាន់ជាមួយឪពុកម្ដាយខ្ញុំ។

ថ្ងៃមួយខ្ញុំបានជួបមិត្តភ័ក្តិរបស់ខ្ញុំម្នាក់ឈ្មោះ ហុង ហើយបានបបួលខ្ញុំទៅរាំលេងជាមួយគាត់ និង មិត្តភ័ក្តិមួយចំនួនទៀត។ ខ្ញុំមានអារម្មណ៍ដូចជាអស់កម្លាំងបន្តិច ហើយដូចជាមិនសូវចង់ទៅជាមួយគេទេ ប៉ុន្តែគាត់និយាយដដែល១ថា ទៅរាំសប្បាយណាស់ ហើយគាត់ជាអ្នកជូនខ្ញុំទៅទីនោះ រួចជូនខ្ញុំមកផ្ទះវិញ នៅពេលរាំចប់។ ឮដូច្នេះខ្ញុំក៏ទៅរាំជាមួយ ហុង និង មិត្តភ័ក្តិមួយចំនួនទៀត ប្រសិនបើខ្ញុំមិនចូលចិត្តនោះ ខ្ញុំនឹងសុំឱ្យគាត់ជូនខ្ញុំមកផ្ទះវិញ។

នៅតាមផ្លូវ ហុង និយាយថា គាត់ចូលទិញភេសជ្ជៈផឹកសិន ដូច្នេះយើងក៏ទៅផ្សារ ហើយទិញស្រាពីរ-បីដប។ ក្រោយមកខ្ញុំបានឡើងជិះម៉ូតូ ហើយហុងបានបើកម៉ូតូទៅទៀត។ យើងជិះម៉ូតូប្រហែល ៥នាទី ទៅដល់កន្លែងដែលយើងត្រូវទៅរាំនោះ។ ខ្ញុំបានប្រុងចុះពីលើម៉ូតូ ប៉ុន្តែ ហុង មិនឈប់ម៉ូតូទេ គាត់បើកម៉ូតូទៅមុខបង្ហួសទៀត។ ខ្ញុំសួរហុងថា ទៅទីណា នៅឯណា? កន្លែងគេរាំនៅឯណោះ យើងហួសឆ្ងាយហើយ ប៉ុន្តែគាត់ និង មិត្តភ័ក្តិនិយាយថាគេឈប់រាំហើយ។ ខ្ញុំមិនជឿពួកគេទេ ដោយខ្ញុំបានឃើញគេរាំ ហើយឮសូរភ្លេងលេងយ៉ាងខ្លាំងផងដែរ។ ខ្ញុំគិតថា ហុងប្រាកដជាធ្លាប់មករាំទីនេះកាលពីមុនរួចហើយ ទើបគាត់ដឹងថាពេលណាចប់កម្មវិធីនោះ។ នៅគ្រានោះខ្ញុំគិតថាវាជារឿងចម្លែក ប៉ុន្តែមិនបានគិតអ្វីផ្សេងទេ។ បន្តិចក្រោយមក យើងក៏បានមកដល់សាលាបឋមសិក្សាមួយ ដោយខ្ញុំគិតថាយើងគ្រាន់តែឈប់ ដើម្បីផឹកស្រាដែលទិញមកពីផ្សារ ហើយនឹងវិលទៅផ្ទះវិញ។

មិត្តភ័ក្តិ ហុង ៦ នាក់ទៀតសុទ្ធតែជាបុរស គេចាំយើងនៅទីនោះ។ យើងទាំងអស់គ្នាអង្គុយចុះ ហើយចាប់ផ្ដើមផឹកស្រា។ ពួកគេទាំងអស់គ្នារួសរាយរាក់ទាក់ណាស់។ មួយសន្ទុះក្រោយមក ខ្ញុំក៏ចាប់ផ្ដើមវិលមុខដោយសារជាតិសុរានោះ ហើយខ្ញុំត្រូវការទៅបន្ទប់ទឹក ដូច្នេះខ្ញុំក៏ទៅកាន់ព្រៃក្បែរនោះ ស្រាប់តែពេលនោះខ្ញុំមានអារម្មណ៍ថាមានអ្នកណាលោតមកចាប់ខ្ញុំ ដោយចាប់ជើង និង ដៃទាំងពីររបស់ខ្ញុំ។ ខ្ញុំក៏ស្រែកយំ រើបំរះដើម្បីព្យាយាមរត់ចេញ។

ខ្ញុំមិនបានដឹងថាមានអ្វីកើតឡើងទៀតទេ ខ្ញុំស្រែក ហើយព្យាយាមចង់ឃើញថាអ្វីកំពុងកើតឡើង។ ខ្ញុំស្រែកហៅ ឈ្មោះ ហុង ឱ្យគាត់ជួយខ្ញុំ។ បន្តិចមក ខ្ញុំក៏មានអារម្មណ៍ថា ហុង និង មិត្តភ័ក្តរបស់គាត់ទាំងអស់ជាអ្នកចាប់ដៃ និង ជើងរបស់ខ្ញុំទាញទៅក្រោម និងចាប់សង្កត់ក្បាលខ្ញុំផងដែរ។ ក្នុងពេលដែលខ្ញុំកំពុងរើបំរះ និង វាយតបទៅវិញនោះ ខ្ញុំនៅតែស្រែក តែពួកវាបានយកដៃមកខ្ទប់មាត់ខ្ញុំជាប់ ដូច្នេះខ្ញុំមិនអាចស្រែកទៀតទេ។

ពួកវាទាំង ៨ នាក់រំលោភខ្ញុំម្ដងម្នាក់។

ខ្ញុំអស់កម្លាំង និង ឈឺចាប់ និង ស្រែកយំយ៉ាងខ្លាំង ។

មួយសន្ទុះក្រោយមក បុរសទាំងអស់នោះចាកចេញពីខ្ញុំ ទុកខ្ញុំចោលក្នុងគម្ពោតព្រៃនោះ ហើយពួកគេ ទៅផឹកស្រាវិញ ។ ខ្ញុំដឹងថា ខ្ញុំត្រូវតែរត់គេចចេញ ។ ខ្ញុំមានការភ័យខ្លាចយ៉ាងខ្លាំង ខ្លាចក្រែងបុរសទាំងនោះចាប់ខ្ញុំធ្វើបាបទៀត ។ ខ្ញុំរត់ទៅឆ្ងាយ ហើយក៏ឃើញផ្ទះមួយនៅជិត ។ ខ្ញុំគោះទ្វារយ៉ាងរន្ថើន ស្រែកឱ្យគេជួយ -ប៉ុន្តែគ្មានមនុស្សណាម្នាក់សោះ ។

ពួកបុរសទាំង ៨ នាក់នោះបានឮសម្លេងខ្ញុំស្រែកឱ្យគេជួយ ហើយរត់មករកខ្ញុំ ។ នៅពេលគេដឹងថា ផ្ទះនោះគ្មានមនុស្សនៅ ពួកគេក៏បានចាប់បង្ខំខ្ញុំឱ្យចូលទៅក្នុងផ្ទះនោះ ហើយរំលោភខ្ញុំម្តងទៀត ។

ខ្ញុំមិនដឹងថាពួកគេរំលោភខ្ញុំអស់រយៈពេលប៉ុន្មានទេ ពីព្រោះខ្ញុំទៅងងឹតមុខ និង សន្លប់ជារៀងរហូត ។ ខ្ញុំដឹងថា ខ្ញុំមានការឈឺចាប់ ។ ខ្ញុំនៅតែគិតរកវិធីរត់គេច ប៉ុន្តែគំនិតខ្ញុំហាក់ដូចជាគិតអ្វីមិនចេញ ដោយពុំមានការជឿជាក់ ។ ខ្ញុំនៅតែមិនជឿថារឿងនេះវាកើតឡើងចំពោះខ្ញុំសោះ ។

ក្រោយពីពួកវារំលោភខ្ញុំក្នុងផ្ទះនោះរួចមក ខ្ញុំព្យាយាមរត់ម្តងទៀតនៅពេលដែលពួកវាភាគច្រើនដេកលក់ ។ ខ្ញុំបន្តរត់ ហើយអ្វីដែលខ្ញុំអាចធ្វើនោះគឺ អស់កម្លាំង ដេកនៅលើដងផ្លូវ ។ ខ្ញុំបានបាត់បង់ស្មារតីម្តងទៀត ។ ខ្ញុំបានឃើញម៉ូតូមួយ មកជិតខ្ញុំ ហើយបុរសម្នាក់ចុះពីលើម៉ូតូ ។ ខ្ញុំដឹងថា គាត់នោះគឺជាមនុស្សម្នាក់ក្នុងចំណោមពួកបុរសទាំង ៨ ដែលបានរំលោភខ្ញុំ ។ ខ្ញុំអស់កម្លាំងខ្លាំងមិនអាចធ្វើអ្វីបានទេ ក៏ចេះតែដេកនៅលើផ្លូវទៅ ។ ខ្ញុំដឹងជាប្រាកដថាគាត់នឹងរំលោភខ្ញុំម្តងទៀត ។ ប៉ុន្តែ មិនដូច្នេះទេ គាត់បានលើកខ្ញុំដាក់លើម៉ូតូគាត់ ហើយឌុបខ្ញុំទៅទម្លាក់ចោលជិតហាងមួយក្បែរផ្ទះខ្ញុំ ។ គាត់មិននិយាយអ្វីទាំងអស់ ហើយខ្ញុំក៏មិនស្គាល់ឈ្មោះគាត់ដែរ ។

ខ្ញុំគិតថាខ្ញុំកំពុងអង្គុយនៅក្បែរហាងមួយអស់រយៈពេលជាយូរម៉ោង មុននឹងខ្ញុំអាចដើរទៅផ្ទះបាន ។ វាហាក់ដូចជាខ្ញុំកំពុងតែស្ថិតក្នុងសុបិន្តអាក្រក់មួយដែលរឿងទាំងនេះហាក់ដូចជាកំពុងតែកើតឡើងចំពោះអ្នកណាម្នាក់ មិនមែនខ្ញុំទេ ។ ពេលខ្ញុំមកដល់ផ្ទះ វាយប់ជ្រៅណាស់ទៅហើយ រីឯឪពុកម្តាយខ្ញុំកំពុងតែបារម្ភពីខ្ញុំយ៉ាងខ្លាំង ។ នៅពេលដែលពួកគាត់ឃើញខ្ញុំ ម្តាយខ្ញុំស្រែកឡើងដោយឃើញខ្ញុំមានស្នាមពេញខ្លួននៅពេលដែលពួកមនុស្សប្រុសទាំងនោះវាយខ្ញុំផ្តួលដើម្បីបង្ខំចាប់រំលោភ ។

ខ្ញុំមិនចង់ប្រាប់ឪពុកម្តាយខ្ញុំនូវអ្វីដែលបានកើតឡើងទេ ខ្ញុំមានការអាម៉ាស់ជាខ្លាំងអំពីរឿងដែលកើតឡើងបែបនេះ ។ ខ្ញុំមិនចង់នាំភាពអាម៉ាស់ និង បាត់បង់កិត្តិយសឱ្យគ្រួសារខ្ញុំទេ ។ មួយសន្ទុះក្រោយមកឪពុកម្តាយខ្ញុំបង្ខំឱ្យនិយាយប្រាប់គាត់អំពីរឿងរ៉ាវដែលបានកើតឡើង ។ ឪពុកខ្ញុំខឹងយ៉ាងខ្លាំង គាត់ហៅខ្ញុំថា "មីសំផឹង" ហើយនេះគឺជាកំហុសរបស់ខ្ញុំ ។ ខ្ញុំនៅតែស្ងៀមមិននិយាយអ្វីទាំងអស់ ។ ម្តាយខ្ញុំឈ្លោះជជែកតមាត់ជាមួយឪពុកខ្ញុំ ហើយ

និយាយថា យើងត្រូវតែទៅប្ដឹងនគរបាល ហើយត្រូវតែរកពួកប្រុសៗទាំងនោះឱ្យឃើញ ។ ចុះបើពួកវាមកហើយចាប់ខ្ញុំទៀត ឬចាប់ស្ត្រីណាមួយនៅក្នុងភូមិ តើធ្វើយ៉ាងម៉េចទៅ?

ពេលថ្ងៃរះម្ដាយខ្ញុំបានជជែកគ្នាជាមួយឪពុកខ្ញុំអស់រយៈពេលយ៉ាងយូរ គាត់ក៏ឯកភាពតាមអ្វីដែលម្ដាយខ្ញុំបាននិយាយ ។ ពួកគាត់នាំខ្ញុំទៅស្នងការនគរបាលខេត្ត ហើយយើងប្ដឹងនៅទីនោះ ។ នគរបាលនៅទីនោះក៏មិនខ្នះខ្នែងជួយប៉ុន្មានដែរ គេប្រាប់ខ្ញុំថា ពិបាករកមនុស្សប្រុសទាំង ៨ នាក់នោះណាស់ ។ ទោះបីជា ហុង ធ្លាប់ជាមិត្តភ័ក្ដិខ្ញុំ ហើយស្គាល់គាត់យ៉ាងណាក៏ដោយ ។

បន្ទាប់ពីជួបនគរបាលរួចហើយ ឪពុកម្ដាយខ្ញុំបាននាំខ្ញុំទៅជួបអង្គការមួយ ដើម្បីដាក់ពាក្យបណ្ដឹងទៀត ។ អង្គការបានរៀបចំឱ្យខ្ញុំស្នាក់នៅក្នុងមណ្ឌលមួយដែលសម្រាប់តែស្ត្រីដូចខ្ញុំដែរ ជាស្ត្រីដែលធ្លាប់រងនូវអំពើហិង្សា ដូច្នេះខ្ញុំអាចមានសុវត្ថិភាពពីបុរសៗដែលរំលោភខ្ញុំ ។

ឥឡូវនេះ ខ្ញុំឆ្លងកាត់ពីមួយថ្ងៃទៅមួយថ្ងៃយ៉ាងសន្សឹមៗ ។ នៅក្នុងមណ្ឌលរៀងរាល់ថ្ងៃ ខ្ញុំរៀន ដាំស្ល និងរៀនអាន និង សរសេរអក្សរខ្មែរ ។ យើងក៏មានកម្មវិធីមួយហៅថា ការពិគ្រោះយោបល់ ដែលយើងត្រូវនិយាយអំពីអារម្មណ៍របស់យើង អំពីរឿងរ៉ាវអាក្រក់ដែលបានកើតឡើង ។ ខ្ញុំមិនចង់នឹកគិតពីរឿងដែលបានកើតឡើងចំពោះខ្ញុំនោះទេ ឬនិយាយរឿងនេះប្រាប់អ្នកណាម្នាក់ទេ ។ ខ្ញុំមានសុបិន្តអាក្រក់ជារៀងរាល់យប់អំពីពេលដែលកើតរឿងអាក្រក់នោះ ហើយខ្ញុំភ្ញាក់ឡើងស្រែកយំ ។ ខ្ញុំមិនចង់នៅត្រង់ណាដែលមាន មនុស្សប្រុសច្រើនទេ ហើយខ្លាចនៅពេលដែលនៅតែឯង ។ ក្នុងពេលឆាប់ៗខាងមុខនេះ ខ្ញុំនឹងត្រូវត្រឡប់ទៅផ្ទះវិញ ហើយខ្ញុំមានអារម្មណ៍ខ្លាចតែជួបប្រុសៗទាំងនោះ ឬ ខ្លាចមនុស្សណាផ្សេងធ្វើបាបខ្ញុំទៀត ។

ខ្ញុំក៏បារម្ភណ៍ផងដែរថា ខ្ញុំនឹងមិនមានអ្នកណារៀបការជាមួយខ្ញុំទេ ពីព្រោះនៅកម្ពុជា បុរសនឹងរៀបការតែជាមួយស្ត្រីណាដែលនៅព្រហ្មចារី ។ ប៉ុន្តែជាថ្មីម្ដងទៀត ខ្ញុំក៏មិនដឹងថាតើខ្ញុំចង់រៀបការដែរ ឬអត់ទេ ។ ខ្ញុំមិនគិតថានឹងជួបបុរសដែលខ្ញុំចូលចិត្តនឹងទុកចិត្តបានដែរ ឬទេ ។

## បញ្ហារំលោភសេពសន្ថវៈជាពួក : រឿងរបស់ដេត

### *ភាពរន្ធត់ និង អាម៉ាស់*

ករណីរបស់ដេតជាការបញ្ជាក់ នូវទម្រង់រំលោភមួយប្រភេទ ពិសេសនៅកម្ពុជា — ការរំលោភជាពួកលើស្ត្រីភេទ ដោយបុរសមួយចំនួនច្រើនពីម្នាក់ឡើងទៅ។ ដេត គឺជាជនរងគ្រោះម្នាក់ដែលរងដោយអំពើហិង្សាព្រៃផ្សៃ និងការរំលោភក្នុងរយៈពេលមួយយ៉ាងយូរ។ នៅមានជនរងគ្រោះបែបនេះជាច្រើនទៀតដែរ ដេតមិនហ៊ាននិយាយប្រាប់គ្រួសារអំពីការរំលោភជាពួកនេះទេ ពីព្រោះវាជារឿងអាម៉ាស់ ហើយខ្លាចថានាងត្រូវស្តីបន្ទោសអំពីរឿងនេះ។ ភាពរន្ធត់ដែលជនរងគ្រោះជួបប្រទះដូចជា ដេតនេះគឺកាន់តែធ្ងន់ធ្ងរឡើងដោយសារកំហឹង ខ្វះជំនឿ និង ការស្តីបន្ទោសដែលជនរងគ្រោះប្រឈមជាមួយនឹងគ្រួសារ ឬមិត្តភ័ក្តិ ប្រសិនបើគេមិនព្រមលាតត្រដាងនូវអំពើរំលោភនោះទេ។ នៅក្នុងករណីរបស់ដេត ឪពុករបស់នាងខឹងយ៉ាងខ្លាំង ហើយនិយាយថា អំពើរំលោភនេះប្រាកដជាបណ្តាលមកពីកំហុសរបស់នាង។



### *ទម្រង់នៃអំពើរំលោភសេពសន្ថវៈ និង ឥរិយាបទដែលជុំរុញឱ្យមាន*

ករណីរបស់ដេតគឺ ជាករណីមួយបែបក្នុងចំណោមករណីមួយចំនួនដែលករណីរំលោភជាក្រុមកើតឡើងនៅកម្ពុជា។ នាងជាមិត្តភ័ក្តិរបស់បុរសម្នាក់ដែលរំលោភនាង ហើយបុរសនោះជាផ្នាក់ទាក់យកមិត្តភ័ក្តិឱ្យធ្លាក់ទៅក្នុងអំពើរំលោភជាពួក។ គាត់ធ្វើជាអញ្ជើញនាងទៅចូលរួមក្នុងកម្មវិធីរាំវែកមួយ ប៉ុន្តែផ្ទុយទៅវិញ គាត់បាននាំនាងទៅកន្លែងស្ងាត់មួយ ដែលមិត្តភ័ក្តិប្រុសៗមួយចំនួនកំពុងរង់ចាំនៅទីនោះ ដើម្បីរំលោភនាង ។

ទម្រង់ជាទូទៅនៃការរំលោភជាពួកមួយទៀតនៅកម្ពុជាគឺ ការរំលោភស្ត្រីរកស៊ីផ្លូវភេទដោយបុរសជាច្រើនជាអំពើដែលគេស្គាល់ជាទូទៅថា "ការរំលោភបូក"។ ជាធម្មតា បុរសម្នាក់ឬ ពីរនាក់ទៅទាក់ទងស្ត្រីរកស៊ីផ្លូវភេទមកដេក ហើយយកនាងទៅកន្លែងមួយដែលនាងមិនស្គាល់ ហើយមានបុរសៗចាំនៅទីនោះស្រាប់ ដើម្បីរំលោភនាង។ ការរំលោភបែបនេះជាធម្មតាច្រើនតែប្រព្រឹត្តដោយកូនសិស្សប្រុសៗ ជាពិសេសនៅភ្នំពេញដែលភាគច្រើនពុំបានគិតពិចារណាថាជាអំពើរំលោភទេ ពីព្រោះជនរងគ្រោះគឺ ជាស្រីរកស៊ីផ្លូវភេទទៅហើយ។ ការសិក្សាមួយរកឃើញថាឥរិយាបទបែបនេះគឺ ប្រព្រឹត្តដោយយុវជនក្មេងៗនៅភ្នំពេញ។ ការសិក្សារកឃើញថាមានតែ ១៣ ភាគរយនៃបុរស និង ស្ត្រីប៉ុណ្ណោះដែល "ទទួលស្គាល់នូវទំនាក់ទំនងផ្លូវភេទដោយបង្ខំរវាងស្ត្រីរកស៊ីផ្លូវភេទម្នាក់ និង

បុរសច្រើននាក់ថា ជាការរំលោភសេពសន្ថវៈ ឬជាការខុស ពីព្រោះស្ត្រីរកស៊ីផ្លូវភេទមិនយល់ព្រមរួមភេទបែប នេះទេ។"[២៨]

ប៉ុន្តែស្ត្រីរកស៊ីផ្លូវភេទពុំមែនជាជនរងគ្រោះតែម្នាក់ឯងពីសំណាក់ការរំលោភជាពួកឡើយ។ "ស្ត្រីវ័យក្មេងណាដែលគេយល់ថា ជាអ្នកធ្វើឱ្យខូចដល់ប្រពៃណីសង្គម និងការរក្សាប្រពៃណីផ្លូវភេទរបស់ប្រទេសជាតិនោះ គឺជាគោលដៅនៃការរំលោភបូក ហើយស្ត្រីបែបនេះទំនងជាមិនសូវហ៊ានតវ៉ា និង វាយតបវិញ ដូចស្ត្រីរកស៊ីផ្លូវភេទទេ។ យុវជនមួយចំនួនក៏អាចជាអ្នករៀបចំ និង ចូលរួមក្នុងការរំលោភជាពួកលើសង្សាររបស់ខ្លួនដោយគេយល់ថា នេះគឺជាវិធីមួយដែលអាចគាបសង្កត់សង្សាឱ្យព្រមរៀបការជាមួយ ឬសន្យារៀបការជាមួយខ្លួនដែលនេះគឺជាមធ្យោបាយដ៏ឃោរឃៅខុសប្រពៃណីមួយ ដើម្បីយកឈ្នះលើនាង។"[២៩]

អំពើរំលោភជាពួកនៅកម្ពុជា ត្រូវបានដក់ជាប់នៅក្នុងតរិយាបទ និង ជំនឿជាទូទៅក្នុងចំណោមយុវជនក្មេងៗដែលបង្កើតឱ្យមានជំនឿថា ស្ត្រីណាដែលមិនអាចចាត់ទុកថាជាស្ត្រីល្អតទៅទៀតនោះ គឺជាស្ត្រីដែលអាចទាក់យកទៅរួមភេទបានដោយពុំចាំបាច់មានការយល់ព្រមពីនាងឡើយដោយសារតែនាងត្រូវបានគេឱ្យតម្លៃថា ជាស្ត្រីមិនបរិសុទ្ធ (ហេតុនេះហើយ"ជាស្ត្រីជិតដាមដោយភាពក្រខ្វក់ដូចសំពត់ប្រឡាក់ភក់")។[៣០]

នៅក្នុងករណីរបស់ ដេត ជាការពិតនាងគ្រាន់តែយល់ព្រមទៅចូលរួមក្នុងពិធីជាមួយមិត្តប្រុសរបស់នាង ហើយផឹកស្រាជាមួយគាត់ និងមិត្តភ័ក្តិរបស់គាត់តែប៉ុណ្ណោះ - នៅក្នុងគំនិតរបស់ពួករំលោភនាង អាចមានគំនិតអ្វីមួយដែលរៀបចំផែនការប្រព្រឹត្តអំពើហិង្សារំលោភរបស់ពួកគេមកលើនាងរួចហើយ។

ការប្រឹងប្រែងផ្នែកសង្គមត្រូវតែមាន ដើម្បីប្រយុទ្ធប្រឆាំងនឹងការរំលោភជាពួកនៅកម្ពុជា រួមមានការអប់រំដល់បុរសៗ និងសាធារណជនទូទៅឱ្យយល់ថាអំពើរួមភេទណាដែលប្រព្រឹត្តទៅបង្ខំដោយពុំមានការយល់ព្រមពីភាគីខាងស្ត្រីគឺចាត់ទុកជាអំពើរំលោភសេពសន្ថវៈ។ កែលំអសេវាកម្មស្តារលទ្ធភាពពលកម្មសម្រាប់ជនរងគ្រោះដោយអំពើរំលោភជាពួក ក៏ដូចជាអប់រំគ្រួសារ និង សហគមន៍របស់ពួកគេដើម្បីឱ្យមានការគាំទ្រយ៉ាងខ្លាំងក្លាដល់ជនរងគ្រោះ ។

---

[២៨] Op Cit 18, P23 Citting Paupers and Princelling: តរិយាបទយុវជនចំពោះករណីរំលោភជាពួក – ហិង្សា រំលោភសេពសន្ថវៈ និង គ្រឿងញៀន ។

[២៩] ការប្រយុទ្ធតទល់នឹងប្រពៃណីសង្គមកម្ពុជា (Janifer Hyman, Global Health Coucil, 2007)

[៣០] OP Cit 18 p.10. citing: កុមារ និង យុវជនដែលត្រូវរំលោភផ្លូវភេទ និង ធ្វើអាជីវកម្មផ្លូវភេទនៅកម្ពុជា ។ ការវាយតម្លៃនូវតម្រូវការសុខភាព និងសេវាកម្មដែលមានស្រាប់នៅក្នុងខេត្តមួយចំនួន ។(អង្គការសហប្រជាជាតិ គណកម្មាធិការសេដ្ឋកិច្ច និង សង្គមសម្រាប់អាស៊ី និង តំបន់ប៉ាស៊ីហ្វិក- ញូវយ៉ក ឆ្នាំ ២០០០) ។

## ករណីរំលោភជាពួកដែលបានរាយការណ៍

ទំហំនៃអំពើរំលោភជាពួកនៅក្នុងប្រទេសគឺមិនអាចដឹងបានទេ ពីព្រោះចំនួនករណីដែលបានរាយការណ៍គឺទំនងជាតែមួយភាគប៉ុណ្ណោះនៃចំនួនករណីពិត ។ ជនរងគ្រោះជាច្រើនពុំបានរាយការណ៍ករណីរបស់ខ្លួនដោយសារភាពអាម៉ាស់។ ជាពិសេស ស្ត្រីរកស៊ីផ្លូវភេទដែលត្រូវរំលោភជាពួក ជាការពិតណាស់ភាគច្រើន មិនប្តឹងទៅនគរបាល ឬអាជ្ញាធរទេ - ការរើសអើងជាទូទៅប្រឆាំងនឹងស្ត្រីរកស៊ីផ្លូវភេទ មានន័យថាបណ្តឹងរបស់ពួកគេទំនងជាមិនត្រូវបានចាត់ការហ្មត់ចត់ដែរ ។

នៅឆ្នាំ ២០០៦ លីកាដូ បានទទួលបណ្តឹងអំពើរំលោភជាពួកពីស្ត្រី ១០ នាក់ ដោយរួមទាំង ដេត ផងដែរ។ ដេត គឺជាជនរងគ្រោះផ្លូវភេទម្នាក់ដែលត្រូវរំលោភដោយបុរសលើសពី ៣ នាក់នៅក្នុងការរំលោភតែមួយដង។ ករណីរំលោភជាពួកដែលបានរាយការណ៍បានកើនឡើងលើសពីឆ្នាំមុន ។

**ករណីរំលោភជាពួកសរុបរាយការណ៍ដោយ លីកាដូ ពីឆ្នាំ ២០០៣-២០០៦**




លីកាដូក៏បានឃ្លាំមើលករណីរំលោភជាពួកដែលបានរាយការណ៍នៅក្នុងកាសែត កម្ពុជា និង កាសែតបរទេសមួយចំនួន និងប្រព័ន្ធឃោសនាផ្សេងទៀតផងដែរ[៣១] ។ ចាប់ពីឆ្នាំ ២០០៤-២០០៦ ចំនួនករណីរំលោភជាពួកដែលបានរាយការណ៍គឺនៅថេរដដែលដោយពុំមានការកើនឡើងទេ។ ប៉ុន្តែ ពីព្រោះអំពើរំលោភជាពួកភាគច្រើន

[៣១] សារព័ត៌មានដែលត្រូវបានឃ្លាំមើលមានរស្មីកម្ពុជា កម្ពុជាថ្មី កោះសន្តិភាព និង Cambodia Daily.

មិនសូវត្រូវបានរាយការណ៍នៅតាមប្រព័ន្ធឃោសនាជាការលំបាកក្នុងការធ្វើសេចក្ដីសន្និដ្ឋាន ថាតើអំពើរំលោភជាពួក មានការកើនឡើងដែរ ឬទេនៅកម្ពុជា ។

**ករណីរំលោភជាពួកសរុបដកស្រង់ពីប្រព័ន្ធផ្សព្វផ្សាយពីឆ្នាំ ២០០៤-២០០៦**




## ការឆ្លើយតបរបស់រាជរដ្ឋាភិបាលចំពោះអំពើរំលោភសេពសន្ថវៈ[៣២]

សេចក្ដីព្រាងផែនការទប់ស្កាត់របស់ក្រសួងកិច្ចការនារី ស្ដីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី ដែលនៅមិនទាន់អនុម័តដោយរាជរដ្ឋាភិបាលនៅឡើយនោះ ពុំឃើញមានកម្មវិធីជាក់លាក់ណាមួយឡើយដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើរំលោភសេពសន្ថវៈនេះ ។

ស្រដៀងគ្នានេះដែរ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិរបស់រាជរដ្ឋាភិបាល ឆ្នាំ ២០០៦- ២០១០ ដែលបានដាក់ចេញនូវយុទ្ធសាស្ត្រ និង សកម្មភាពកាត់បន្ថយអំពើហិង្សាលើស្ត្រី ក៏ពុំឃើញមានចំណុចណាមួយចែងឱ្យបានជាក់លាក់អំពីអំពើរំលោភសេពសន្ថវៈនេះដែរ ។

ក្នុងកំឡុងពេលសាកសួរដោយគណកម្មាធិការ CEDAW កាលពីថ្ងៃទី ១៩ មករា ១៩៩៦ តំណាងក្រសួងកិច្ចការនារីលើកឡើងថា ក្រសួងបានបង្កើតឱ្យមានការិយាល័យរំលោភសេពសន្ថវៈ[៣៣] ។

---

៣២ ចំពោះព័ត៌មានបន្ថែមស្ដីអំពីគោលនយោបាយបច្ចុប្បន្ន និង អតីតកាលរបស់រដ្ឋាភិបាល សូមអានឯកសារ អំពើហិង្សាលើស្ត្រីនៅកម្ពុជា ( លីកាដូ ខែ មករា ឆ្នាំ ២០០៦ ) ទំ. ៨ ។

៣៣ Op Cit 13.

ប៉ុន្តែពុំមានព័ត៌មានណាមួយបញ្ជាក់អំពីតួនាទី និង មុខងាររបស់ការិយាល័យនោះទេ។ សមាជិកគណកម្មាធិការម្នាក់និយាយថា " វិធីដែលរដ្ឋមួយដាក់បទល្មើសនោះឱ្យទៅជាបទឧក្រិដ្ឋ គឺវាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងបទដ្ឋានវប្បធម៌។គេបានរាយការណ៍ប្រាប់គណកម្មាធិការថា កាលពីអតីតកាលមានករណីរំលោភជាច្រើនដែលមិនត្រូវបានរាយការណ៍នៅកម្ពុជា។ បច្ចុប្បន្ននេះគណកម្មាធិការបានឮថា ការិយាល័យរំលោភសេពសន្ថវៈត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហា...ព្រមទាំងរៀបចំទទួលព័ត៌មានបន្ថែមអំពីបញ្ហានេះ។ តើការិយាល័យនេះមានធ្វើការងារពាក់ព័ន្ធនឹងការហ្វឹកហ្វឺន មន្ត្រីអនុវត្តច្បាប់ និង ប្រឹងប្រែងដើម្បីផ្លាស់ប្តូរវប្បធម៌មើលស្រាលទូទៅដែរឬទេ?

រាជរដ្ឋាភិបាលកម្ពុជាមិនឆ្លើយនឹងសំណួរនេះទេ ។



លីកាដូទើបតែបានដឹងពីប្រធានការិយាល័យរំលោភថា ការិយាល័យនេះត្រូវបានបង្កើតឡើងកាល ពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៦ កន្លងទៅ[៣៤] ។ គោលបំណងនៃការិយាល័យនេះគឺដើម្បីជួយជនរងគ្រោះ ប្រសិនបើ ពួកគេស្វែងរកជំនួយសេវាកម្មផ្នែកច្បាប់។ ការិយាល័យរំលោភសេពសន្ថវៈផ្តល់ជំនួយ ដោយការនាំជនរងគ្រោះទៅរកអង្គការនានា[៣៥] ដែលអាចជួយផ្តល់ការប្រឹក្សាផ្នែកច្បាប់នឹងជួយពួកគេក្នុងការដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌ។ នៅក្នុងសេវាកម្មរបស់រាជរដ្ឋាភិបាលដែលមានស្រាប់ ដើម្បីជួយជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈប្រាកដជាមានការខ្វះចន្លោះ ។

□□□

[៣៤] ព័ត៌មានទទួលបានតាមរយៈការសន្ទនាតាមទូរស័ព្ទរវាងបុគ្គលិកលីកាដូ និង អ្នកស្រី ហែម សុខ ប្រធានការិយាល័យ រំលោភសេពសន្ថវៈ ក្រសួងកិច្ចការនារី កាលពីថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៧ ។

[៣៥] មជ្ឈមណ្ឌលកម្ពុជាដើម្បីស្ត្រីមានវិបត្តិ ។

# ៤. អំពើជួញដូរមនុស្សក្នុងគោលបំណងអាជីវកម្មផ្លូវភេទ

**ក្នុងជំពូកនេះ...**

**ករណីសិក្សា ៤ : អំពើជួញដូរមនុស្ស និង ដើម្បីធ្វើអាជីវកម្មផ្លូវភេទ**

**បញ្ហាអំពើជួញដូរមនុស្ស: រឿងរ៉ាវរបស់ ហេង ណារី**

- *កង្វះការអនុវត្តច្បាប់ និង និទ្ទណ្ឌភាព*
- *អាជីវកម្មផ្លូវភេទ និង ពេស្យាចារ*
- *កង្វះវិធានការ ការវិលត្រឡប់ទៅផ្ទះសម្បែងវិញ ការធ្វើសមាហរណកម្ម និង ស្តារនីតិសម្បទារ*
- *បញ្ហាធ្ងន់ធ្ងរមួយចំនួនទៀត*
- *តើគេត្រូវប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សដោយរបៀបណាជាមួយករណីដូចណារី ?*
- *សេចក្តីព្រាងច្បាប់ស្តីពីអំពើជួញដូរមនុស្ស និង អាជីវកម្មផ្លូវភេទ*

**ករណីជួញដូរមនុស្ស ដើម្បីគោលបំណងអាជីវកម្មផ្លូវភេទដែលបានរាយការណ៍**

**ការឆ្លើយតបរបស់រាជរដ្ឋាភិបាលចំពោះអំពើជួញដូរមនុស្ស ដើម្បីគោលបំណងអាជីវកម្មផ្លូវភេទ**

- *គោលនយោបាយ និង ផែនការរបស់រាជរដ្ឋាភិបាល*
- *កិច្ចព្រមព្រៀងអង្គការមិនមែនរដ្ឋាភិបាល*
- *ពិធីសារអង្គការសហប្រជាជាតិស្តីពីអំពើជួញដូរមនុស្ស*

អំពើជួញដូរស្ត្រីគឺជាអំពើខុសច្បាប់តាមច្បាប់ស្តីពីការបង្ក្រាបអំពើចាប់ជំរិត ជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និង អំពើកេងប្រវ័ញ្ចមនុស្ស[៣៦] និង ច្បាប់រដ្ឋធម្មនុញ្ញ[៣៧] ។ ច្បាប់ទាំងនេះបានកំណត់អំពើនេះ ជាអំពើខុសច្បាប់ដូចជាអំពើចាប់ជំរិតមនុស្សដើម្បីជួញដូរ ឬ លក់ ឬយកទៅធ្វើជាស្ត្រីរកស៊ីផ្លូវភេទ។[៣៨]

លក្ខណដាច់ពីគ្នានៃអំពើជួញដូរ គឺការប្រើប្រាស់កម្លាំង ការបង្ខិតបង្ខំ ឬការបោកប្រាស់ក្នុងគោលបំណងយកទៅធ្វើអាជីវកម្ម ។

**ករណីសិក្សា ៤ : អំពើជួញដូរមនុស្ស និង ដើម្បីធ្វើអាជីវកម្មផ្លូវភេទ**

*ខ្ញុំឈ្មោះ ហេង ណារី អាយុ ២០ឆ្នាំ ខ្ញុំធ្លាប់ត្រូវបានគេជួញដូរនឹងបង្ខំឱ្យធ្វើជាស្ត្រីរកស៊ីផ្លូវភេទ។ ខាងក្រោមនេះ គឺជារឿងរ៉ាវរបស់ខ្ញុំ។*

*ខ្ញុំរស់នៅជាមួយម្តាយខ្ញុំ។ ម្តាយខ្ញុំប្រាប់ថា ខ្ញុំមានបញ្ហាផ្លូវចិត្ត - ខ្ញុំមិនយល់ពីអត្ថន័យសំដីដែលគាត់និយាយនោះទេ។ គាត់តែងតែប្រាប់ថា ខ្ញុំធ្វើដូចជាកូនក្មេង ដូច្នេះខ្ញុំមិនអាចគិតអ្វីដូចមនុស្សចាស់ទេ។ ថ្ងៃមួយ ពូខ្ញុំនិយាយថា ខ្ញុំមានជម្ងឺផ្លូវចិត្ត ហេតុនេះខ្ញុំពុំមានការផ្លាស់ប្តូរអ្វីទេ។*

---

[៣៦] ច្បាប់ស្តីពីការបង្ក្រាបអំពើចាប់ជំរិត ជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ និងអំពើកេងប្រវ័ញ្ចមនុស្ស មាត្រា ២ ។

[៣៧] រដ្ឋធម្មនុញ្ញ មាត្រា ៤៦ ។

[៣៨] ច្បាប់ស្តីពីការបង្ក្រាបអំពើចាប់ជំរិត ជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ និងអំពើកេងប្រវ័ញ្ចមនុស្ស មាត្រា ៣ ។

ខ្ញុំក៏មិនយល់សំដីគាត់ថាយ៉ាងម៉េចដែរ ។

ថ្ងៃមួយពេលខ្ញុំកំពុងដើរលេងនៅជិតៗផ្ទះស្រាប់តែមានស្ត្រីស្អាតម្នាក់មកជួបខ្ញុំ ហើយនិយាយជាមួយខ្ញុំ។ ខ្ញុំមិនចាំថាមានអ្វីកើតឡើងបន្ទាប់ពីពេលនោះទេ ប៉ុន្តែគាត់បាននាំខ្ញុំទៅឆ្ងាយពីភូមិរបស់ខ្ញុំ ។ ពេលដែលដឹងខ្លួនឡើង ខ្ញុំស្ថិតនៅក្នុងបន្ទប់មួយ។ ខ្ញុំភ័យយ៉ាងខ្លាំង ហើយខ្ញុំបានស្រែកហៅគេឱ្យជួយ ។ ពេលនោះ មានស្ត្រីម្នាក់ចូលមក ហើយនិយាយថា គាត់ជាម្ចាស់ថ្មីរបស់ខ្ញុំ។ គាត់ប្រាប់ខ្ញុំថា គាត់ឈ្មោះ ឡាយ សុភាព ។ ខ្ញុំមិនយល់ថា គាត់កំពុងនិយាយអ្វីទេ ខ្ញុំបានព្យាយាមក្រោកឡើងទៅរកម្តាយខ្ញុំវិញ។ ប៉ុន្តែ នាងនោះបានចាប់ឃាត់ខ្ញុំទុក ហើយនិយាយថា ខ្ញុំជំពាក់លុយគាត់ ដូច្នេះខ្ញុំត្រូវតែធ្វើការឱ្យគាត់ដើម្បីកាត់បំណុល។

មានរឿងអាក្រក់ជាច្រើនបានកើតឡើង ដែលទាំងអស់នេះខ្ញុំនៅតែមិនយល់។ ខ្ញុំនៅចាំបានថា មានបុរសម្នាក់ចូលមក ហើយគាត់បានដេកពីលើខ្ញុំ។ បុរសនោះបានឱ្យលុយខ្ញុំ ៥000 រៀល នៅពេលគាត់ចេញទៅវិញ ប៉ុន្តែស្ត្រីឈ្មោះ សុភាព ចូលមក ហើយដកយកលុយខ្លះពីខ្ញុំប្រហែលពាក់កណ្តាល។ គាត់និយាយថា ខ្ញុំត្រូវតែបង់លុយថ្លៃម្ហូបអាហារ និង ថ្លៃរស់នៅឱ្យគាត់។

រឿងដូចនេះបានកើតឡើងចំពោះខ្ញុំជារៀងរាល់ថ្ងៃ។ ខ្ញុំឈឺច្រើនដងណាស់ហើយខ្ញុំចង់ស្រែក ប៉ុន្តែសុភាពទះកំផ្លៀងខ្ញុំ ព្រមទាំងប្រាប់ថានេះហើយ គឺជាការងាររបស់ខ្ញុំ។ ខ្ញុំនឹកផ្ទះ និង ម្តាយ ខ្ញុំចង់តែរត់ចេញ។ ខ្ញុំមិនយល់ថា ហេតុអ្វីបានជាត្រូវធ្វើការបែបនេះឱ្យសុភាពទេ។

ថ្ងៃមួយពេលខ្ញុំកំពុងអង្គុយនៅខាងក្រៅ ខ្ញុំបានឃើញស្ត្រីម្នាក់មកពីភូមិខ្ញុំ។ នាងឈ្មោះ ធារី ហើយនាងធ្លាប់រាប់អានជាមួយខ្ញុំដែរកាលពីមុន។ ពេលដែលនាងឃើញខ្ញុំ ធារីចូលមកហើយនិយាយសាកសួរខ្ញុំថា ឯងធ្វើការងារអ្វីនៅឆ្ងាយពីភូមិម្ល៉េះ? ខ្ញុំបានប្រាប់ធារីថា ខ្ញុំត្រូវតែធ្វើការឱ្យសុភាព ខ្ញុំមិនដឹងថាហេតុអ្វីទេ ហើយក៏មិនយល់ថាហេតុអ្វីបានជាមនុស្សប្រុសមកដេកជាមួយជារៀងរាល់ថ្ងៃដែរ។ ខ្ញុំបានសុំឱ្យនាងប្រាប់ម្តាយខ្ញុំផង ដើម្បីឱ្យគាត់មកយកខ្ញុំទៅផ្ទះវិញ។

ពីរ-បី ថ្ងៃក្រោយមក មានមនុស្សមកជួបខ្ញុំនៅផ្ទះសុភាព ហើយប្រាប់ខ្ញុំថា ខ្ញុំនឹងឈប់ធ្វើការនៅផ្ទះសុភាពទៀតហើយ។ ខ្ញុំយំយ៉ាងខ្លាំងពីព្រោះភ័យខ្លាច។ ប៉ុន្តែមនុស្សនោះប្រាប់ខ្ញុំថា កុំភ័យអ្វី បន្តិចទៀតខ្ញុំបានជួបម្តាយខ្ញុំវិញហើយ។

គេបាននាំខ្ញុំត្រឡប់មកផ្ទះវិញ យើងធ្វើដំណើរយ៉ាងយូរ ខ្ញុំបានជួបម្តាយខ្ញុំវិញមែន ម្តាយខ្ញុំស្រែកយំ ហើយឱបខ្ញុំ។ ខ្ញុំមិនដឹងថាហេតុអ្វីបានជាគាត់យំទេ ប៉ុន្តែខ្ញុំសប្បាយចិត្តណាស់នៅពេលបានត្រឡប់មកផ្ទះវិញ។

## បញ្ហាអំពើជួញដូរមនុស្សៈ រឿងរ៉ាវរបស់ហេង ណារី

***កង្វះការអនុវត្តន៍ច្បាប់ និង និទ្ទណ្ឌភាព***

ហេង ណារី ត្រូវបានគេចាប់យកពីភ្នំពេញទៅខេត្តមួយយ៉ាងឆ្ងាយ ជាកន្លែងដែលគេបង្ខំនាងឱ្យធ្វើជាស្ត្រីរកស៊ីផ្លូវភេទ។ នាងមានបញ្ហាខាងប្រាជ្ញាស្មារតី ហើយមិនយល់សោះអំពីអ្វីដែលបានកើតឡើង។ ជាសំណាងល្អនាងត្រូវបានរំដោះចេញពីផ្ទះរបស់សុភាព ដែលជាផ្ទះបនពិតប្រាកដ បើតាមព័ត៌មានពីមនុស្សក្នុងភូមិឈ្មោះ ធារី។ លីកាដូ សហការជាមួយនគរបាលប្រឆាំងការជួញដូរមនុស្ស ស្វែងរកនាងណារី ហើយនាំនាងត្រឡប់ទៅផ្ទះវិញ។ នាងមិនអាចចាំរូបរាងស្ត្រីដែលចាប់នាងយកទៅលក់ទេ។ នៅពេលដែល លីកាដូស៊ើបអង្កេតករណីនេះ អ្នកស៊ើបអង្កេតបានរកឃើញថា ផ្ទះរបស់សុភាពគឺជាបនស្រី ហើយណារីត្រូវបានគេជួញដូរ និង បង្ខំឱ្យនាងធ្វើជាស្ត្រីរកស៊ីផ្លូវភេទ។ លីកាដូ ដោយមានកិច្ចសហការជាមួយនគរបាល ប្រឆាំងអំពើជួញដូរមនុស្ស និងអង្គភាពការពារអនីតិជន ស្វែងរកណារីឃើញ ហើយនាំនាងត្រឡប់មកផ្ទះ ជួបជុំម្តាយវិញនៅភ្នំពេញ។ មកដល់ពេលនេះ គ្មាននរណាម្នាក់ត្រូវបានផ្តន្ទាទោសក្នុងករណីនាងណារីនេះឡើយ។

នគរបាលមូលដ្ឋានដែលយកណារីចេញពីផ្ទះបន មិនបានចាប់ម្ចាស់បន ឈ្មោះ សុភាពនោះទេ ។ យោងតាមរបាយការណ៍នគរបាល សុភាពអះអាងថា ណារីបម្រើផ្លូវភេទនៅទីនេះដោយសារការស្ម័គ្រចិត្ត ហើយនាងមិនត្រូវបានគេជួញដូរទេ។ ប៉ុន្តែនគរបាលមូលដ្ឋាននោះពុំបានដេញដោលសួរព័ត៌មានពីសុភាពឱ្យច្រើនទេ។ ដោយសារតែបញ្ហាជម្ងឺផ្លូវចិត្តរបស់នាង ណារីមិនអាចចងចាំភិនភាគស្ត្រីដែលជួញដូរនាងទៅផ្ទះបនរបស់សុភាពទេ។

និទ្ទណ្ឌភាពបែបនេះ ចំពោះអ្នកជួញដូរមនុស្សគឺជារឿងសាមញ្ញនៅកម្ពុជា។ មុខរបរអាជីវកម្មផ្លូវភេទដ៏កាក់កប មានន័យថា អ្នកជួញដូរមនុស្ស ម្ចាស់បន និង មេបនអាចសូកប៉ាន់ដើម្បីគេចផុតពីការចាប់ខ្លួន និងផ្តន្ទាទោស។ នគរបាល យោធា ឬ មន្ត្រីផ្សេងៗទៀត មានការពាក់ព័ន្ធជាច្រើននៅក្នុងបញ្ហានេះ ប្រឹងការពារយ៉ាងសកម្មដល់សកម្មភាពជួញដូរ និង ផ្ទះបន។ ប្រសិនបើមានជនរងគ្រោះប្តឹងពីបទព្រហ្មទណ្ឌ នគរបាល និង តុលាការអាចបង្ខំពួកគេឱ្យដកពាក្យបណ្តឹងជាថ្នូនឹងប្រាក់សំណងដែលសងដោយជនល្មើស។ មានជនល្មើសតិចតួចបំផុតដែលត្រូវបានផ្តន្ទាទោស និង កាត់ទោសឱ្យជាប់ពន្ធនាគារ។ ជាពិសេស "ករណីជួញដូរមនុស្សបានក្លាយជាសោកនាដកម្មមួយ ដែលនិទ្ទណ្ឌភាពបានក្លាយទៅជារបត់គំនិតមួយ នៅពេលណាមានការវិនិច្ឆ័យទោសចំពោះករណីបែបនេះគឺត្រូវ គេចាត់ទុកថាជាភាពមិនធម្មតាទៅវិញ។"[៣៩]

---

[៣៩] របាយការណ៍សិទ្ធិស្ត្រីកម្ពុជា ឆ្នាំ ២០០៤ : សេចក្តីសង្ខេបស្តីពីស្ថានភាពស្ត្រីនៅកម្ពុជា (លីកាដូ ខែ កក្កដា ២០០៤) ទំ. ៨ ។ ស្ថានភាពសិទ្ធិមនុស្ស (សមាគមសិទ្ធិមនុស្ស និង អភិវឌ្ឍន៍ របាយការណ៍ ខែមករា ឆ្នាំ ២០០៤) ទំ. ៤០ ។

## ***អាជីវកម្មផ្លូវភេទ និង ពេស្យាចារ***

គ្មានវិធីសាស្ត្រណាមួយ ដើម្បីវាស់វែងចំនួនស្ត្រីកម្ពុជាដែលគេជួញដូរក្នុងគោលបំណងផ្លូវភេទឱ្យបានត្រឹមត្រូវឡើយ។ ប៉ុន្តែ គេមានជំនឿជាទូទៅថា ជនរងគ្រោះដោយអំពើជួញដូរភាគច្រើនត្រូវគេជួញដូរ ដើម្បីគោលបំណងអាជីវកម្មផ្លូវភេទ ដែលរួមមានអាជីវកម្មពេស្យាចារ។

ជនរងគ្រោះមួយចំនួនត្រូវបានគេចាប់យកទៅធ្វើជាពេស្យាចារ។ ប៉ុន្តែ ជាទូទៅគឺជនរងគ្រោះត្រូវបានគេលួងលោមបោកយកទៅឆ្ងាយបំផុតពីផ្ទះ ដោយមានការសន្យាបោកប្រាស់ថាទៅធ្វើការដូចជា អ្នកបម្រើ និង កម្មករកាត់ដេរជាដើម ឬក៏ពួកគេត្រូវលក់ទៅអ្នកជួញដូរ ឬផ្ទះបនផ្ទាល់តែម្តងដោយគ្រួសារ ឬមិត្តភ័ក្តិជិតស្និទក៏មាន។[៤០] ក្នុងករណីរបស់ណារី ជនល្មើសបានបញ្ឆោត ណារីដោយសារតែបញ្ចោជម្ងឺផ្លូវចិត្ត ដើម្បីអូសទាញនាងឱ្យចាកចេញពីភូមិ និង ផ្ទះសម្បែងរបស់នាង។ នៅពេលដែលនាងទៅដល់ផ្ទះបន គេបានប្រើអំពើហិង្សាលើនាង ដើម្បីបង្ខំនាងឱ្យធ្វើជាស្ត្រីរកស៊ីផ្លូវភេទ ហើយឃាត់ឃាំងនាងមិនឱ្យចាកចេញទៅណាទេ។



ពេស្យាចារដោយបង្ខិតបង្ខំ គឺជាបទឧក្រិដ្ឋធ្ងន់ធ្ងរ ដែលប្រព្រឹត្តហិង្សាហួសហេតុមកលើស្ត្រីនៅកម្ពុជា ហើយវាក៏មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងបទល្មើសរំលោភ។ ណារីត្រូវបានគេរំលោភជាច្រើនលើកច្រើនដងក្នុងមួយថ្ងៃៗ ជាថ្នូរទៅនឹងចំនួនប្រាក់ដ៏តិចតួច ហើយដោយគ្មានការយល់ព្រមពីនាងបន្តិចទាល់តែសោះ។ ជនល្មើសដែលប្រព្រឹត្តក្នុងករណីណារីបានទាញយកផលប្រយោជន៍ពីពិការភាពរបស់នាង ដើម្បីបង្ខំនាងឱ្យក្លាយជា ពេស្យាចារដោយខ្លួនឯង។ ស្ថានភាពណារីពុំមែនបទដ្ឋានមួយក្នុងចំណោមស្ត្រីកម្ពុជាដែលត្រូវបានគេជួញដូរយកទៅធ្វើពេស្យាចារទេ ជនល្មើសបញ្ឆោតជនរងគ្រោះដោយផ្អែកលើភាពទន់ខ្សោយស្រដៀងគ្នានេះដែរដូចជា ភាពក្រីក្រ ចំណងបំណុល ភាពអន់ថយនៃវប្បធម៌ និងការបាត់បង់ព្រហ្មចារីរបស់ជនរងគ្រោះជាដើម ដោយបន្តបង្ខំ ស្ត្រីទាំងនោះឱ្យធ្លាក់ចូលទៅក្នុងពេស្យាចារដោយខ្លួនឯង។

---

[៤០] ចំពោះព័ត៌មានបន្ថែមសូមអានឯកសារ ការពិនិត្យឡើងវិញនៃទសវត្ស នៃការសិក្សាស្រាវជ្រាវស្តីពីអំពើជួញដូរ មនុស្សនៅកម្ពុជា (Annuska Derks, Roger Henke & Ly Vanna, មូលនិធិអាស៊ីសហការជាមួយមជ្ឈមណ្ឌដើម្បីសិក្សាអភិវឌ្ឍន៍ ខែ ឧសភា ឆ្នាំ ២០០៦ ទំ. ២០)។

## *កង្វះវិធានការ ការវិលត្រឡប់ទៅផ្ទះសម្បែងវិញ ការធ្វើសមាហរណកម្ម និង ស្តារនីតិសម្បទារ*

ពេលដែលចង់នាំជនរងគ្រោះដែលត្រូវជួញដូរត្រឡប់ទៅផ្ទះសម្បែងវិញដោយឆ្លងកាត់ព្រំដែនអន្តរជាតិ[៤១] ការខិតខំប្រឹងប្រែងថ្មីៗរបស់រាជរដ្ឋាភិបាល ដើម្បីជួយជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅតែមិនទាន់គ្រប់គ្រាន់នៅឡើយទេ ។ ក៏ដូច ណារីដែរ ជនរងគ្រោះដោយអំពើជួញដូរភាគច្រើន ពឹងផ្អែកទៅលើសេវាកម្មតិចតួចរបស់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីជាវិធានការជួយធ្វើមាតុភូមិនិវត្តិន៍ សមាហរណកម្ម និង ស្តារនីតិសម្បទារដែលរាជរដ្ឋាភិបាលត្រូវប្រឹងប្រែងដើម្បីដោះស្រាយនូវបញ្ហានេះ ។

## *បញ្ហាធ្ងន់ធ្ងរមួយចំនួនទៀត*

មូលហេតុដែលជំរុញតម្រូវការ និង ការផ្គត់ផ្គង់ស្ត្រីត្រូវជួញដូរគឺមានច្រើនជាអនេក ហើយនៅក្នុងប្រទេសដែលវាយលុកដោយភាពក្រីក្រដូចជាកម្ពុជានេះ បញ្ហាទាំងនេះនឹងបង្កើននូវពេលវេលារបស់យើង ។ ឧទាហរណ៍មួយចំនួនរួមមានៈ[៤២]

- ផលប៉ះពាល់នៃសង្គមនៅក្រោយសង្គ្រាម និង ការបែកបាក់នូវតម្លៃវប្បធម៌
- ភាពក្រីក្រ និង ទេសន្តប្រវេសន៍ (ចំណាកស្រុក)
- ចំណងបំណុល

## *តើគេត្រូវប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សដោយរបៀបណា ជាមួយករណីដូច ណារី*

តាមច្បាប់ជួញដូរបច្ចុប្បន្ន ជនល្មើសដែលជួញដូរណារី (អ្នកដែលយកនាងទៅលក់ឱ្យធ្វើជាពេស្យាចារ និងអ្នកដែលទទួលផលពីការរកចំណូលរបស់នាងពីមុខរបរពេស្យាចារ) អាចត្រូវបានផ្តន្ទាទោស ប្រសិនបើរកឃើញថាមានពិរុទ្ធភាព ត្រូវដាក់ពន្ធនាគារពី ១ឆ្នាំ ទៅដល់ ២០ឆ្នាំ យោងទៅតាមបទឧក្រិដ្ឋ។[៤៣]

នគរបាលបានបង្ក្រាបផ្ទះបនដើម្បី "រំដោះ" ស្ត្រីរកស៊ីផ្លូវភេទជាប្រចាំ ដែលនាំឱ្យមានការចាប់ខ្លួនតិចតួច ឬគ្មានការចាប់ខ្លួនសោះ ហើយក្រោយមកផ្ទះបននោះត្រូវបានបើកឡើងវិញក្នុងរយៈពេលប៉ុន្មានថ្ងៃក្រោយមក។ ការផ្តន្ទាទោសដែលធ្លាប់ឃើញធ្វើឡើងជាធម្មតា គឺជាការផ្តន្ទាទោសដល់មេបន ឬអ្នកជួញដូរថ្នាក់ទាបតែប៉ុណ្ណោះ ហើយម្ចាស់បន ឬអ្នកជួញដូរសំខាន់ៗ សូកលុយរត់គេចខ្លួនបាត់។ ក្នុងករណីរបស់ណារី ម្ចាស់ផ្ទះបនឈ្មោះ សុភាព

---

[៤១] សូមអានរបាយការណ៍ចាស់របស់លីកាដូ អំពើហិង្សាលើស្ត្រី (ខែ មករា ២០០៦ ទំ. ១៧ -១៨ ដើម្បីជាព័ត៌មានបន្ថែម ។

[៤២] សូមអានរបាយការណ៍ចាស់របស់លីកាដូ អំពើហិង្សាលើស្ត្រី (ខែ មករា ២០០៦ ទំ. ១៥ -១៧ ដើម្បីជាព័ត៌មានបន្ថែម ។

[៤៣] ច្បាប់ស្តីការបង្ក្រាបអំពើចាប់ជំរិត ជួញដូរ និង អាជីវកម្មផ្លូវភេទលើមនុស្ស ។ មាត្រា ៣-៨ ។

មិនត្រូវបានចាប់ខ្លួន ឬចោទប្រកាន់ទេ នគរបាលទទួលយកការអះអាងរបស់សុភាពដែលថា ណារីបានចូលមកធ្វើជាពេស្យាដោយការស្ម័គ្រចិត្ត ។

ជាធម្មតា អាជ្ញាធរបានព្យាយាមប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សដើម្បីគោលបំណងធ្វើអាជីវកម្មផ្លូវភេទ ដោយបង្ក្រាបផ្ទះបន និង ផ្ទះសំណាក់យូរ១ម្តង ហើយបានរំដោះនារីរកស៊ីផ្លូវភេទ។ វិធីសាស្ត្រនេះនៅមានបញ្ហាមួយចំនួន ដោយជួនកាលស្ត្រីរកស៊ីផ្លូវភេទអះអាងថា ខ្លួនមិនត្រូវបានគេជួញដូរទេ ហើយគេធ្វើដោយការស្ម័គ្រចិត្ត ហើយជាធម្មតាជនល្មើសដែលត្រូវគេចាប់នោះ គឺជាអ្នកដែលទទួលខុសត្រូវផ្ទាល់នៅក្នុងផ្ទះបន ឬអ្នកដែលទទួលផលចំណេញពីនារីរកស៊ីផ្លូវភេទ។ ជនល្មើសពិតប្រាកដកម្រនឹងចាប់បាន ឬត្រូវចោទប្រកាន់ពីបទព្រហ្មទណ្ឌណាស់ ហើយជាធម្មតាគេអាចគេចផុតពីទណ្ឌកម្មនៃបទឧក្រិដ្ឋ។

ទង្វើខាងលើកើតឡើងនៅក្នុងករណីរបស់ណារី ហើយជាឧទាហរណ៍មួយដែលច្បាប់មិនត្រូវបានប្រើប្រាស់ឱ្យអស់ពីសមត្ថកិច្ចដោយម្ចាស់ផ្ទះបនឈ្មោះសុភាពមិនត្រូវបានចោទប្រកាន់ដោយអាជ្ញាធរមានសមត្ថកិច្ចឡើយ។ មូលហេតុមួយចំពោះបញ្ហានេះគឺអាចមកពីច្បាប់មិនបានកំណត់និយមន័យបទឧក្រិដ្ឋជួញដូរឱ្យបានច្បាស់លាស់ហើយមិនកំណត់អ្នកពាក់ព័ន្ធឱ្យច្បាស់នៅក្នុងដំណើរការជួញដូរនេះ។ ជាធម្មតាអំពើជួញដូរមនុស្សតែងមានការពាក់ព័ន្ធជាមួយអ្នកសមគំនិតជាច្រើន ដូចជាអ្នកពាក់ព័ន្ធក្នុងការជ្រើសរើស ដឹកជញ្ជូន ផ្ទេរ នឹង ផ្តល់កន្លែងសំចតដល់មនុស្សដែលត្រូវជួញដូរជាដើម។ ច្បាប់បច្ចុប្បន្នហាក់ដូចជាមិនបានគ្របដណ្តប់ទៅលើជនល្មើសទាំងអស់នេះទេ នៅក្នុងដំណើរការជួញដូរមនុស្ស។

លើសពីនេះទៅទៀត និយមន័យនៃពាក្យជួញដូរគួរតែបញ្ចូលឱ្យបានលំអិតថែមទៀតទាក់ទងទៅនឹងដំណើរការនៃ "ការជ្រើសរើស"។ ច្បាប់បច្ចុប្បន្នត្រឹមតែគ្របដណ្តប់នូវស្ថានភាពដែលជនត្រូវគេជួញដូរម្នាក់ត្រូវបានគេជ្រើសរើស ដោយសន្យាឱ្យលុយ គំរាមកំហែង បង្ខំឱ្យប្រើគ្រឿងញៀន។ នៅមានស្ថានភាពច្រើនថែមទៀតដែលរួមមានការជ្រើសរើសក្នុងការជួញដូរមនុស្សម្នាក់ដោយបន្លំ បោកប្រាស់ រំលោភដោយអំណាច ឬចំណាយប្រាក់ទៅឱ្យអ្នកណាម្នាក់ដែលជាអ្នកត្រួតត្រា ឬ មានឥទ្ធិពល ឬ អ្នកផ្សេង។ (ដូចជាសមាជិក គ្រួសារណាម្នាក់) ឬមនុស្សដែលស្ថិតក្នុងភាពងាយរងគ្រោះ ដូចជា នរណាម្នាក់ ដូចជាណារីជាដើម។ និយមន័យ ដ៏ទូលំទូលាយជាងនេះមួយទៀតគឺ នឹងមកដល់នៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ។

## ***សេចក្តីព្រាងច្បាប់ស្តីពីអំពើជួញដូរមនុស្ស និង អាជីវកម្មផ្លូវភេទ***

សេចក្តីព្រាងច្បាប់ស្តីពីអំពើជួញដូរមនុស្ស និង អាជីវកម្មផ្លូវភេទ អាចផ្តល់ឱ្យនគរបាល និង តុលាការនូវអំណាចច្រើនជាងមុនក្នុងការចាប់ និង ផ្តន្ទាទោសជនល្មើស ហើយផ្តល់ការការពារដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។សេចក្តីព្រាងច្បាប់នេះក៏ផ្តល់និយមន័យជួញដូរមនុស្សទូលំទូលាយជាង ច្បាប់ប្រឆាំងអំពើជួញដូរមនុស្សបច្ចុប្បន្នផងដែរហើយបានកំណត់និយមន័យនៃពាក្យជួញដូរមនុស្សថាជាៈ[៤៤]

១. អំពើជួញដូរមនុស្ស គឺមានន័យថា អំពើបញ្ជូនមនុស្សដោយខុសច្បាប់ពីម្នាក់ទៅម្នាក់ទៀត ឬការទទួលយកមនុស្សដោយខុសច្បាប់ពីនរណាម្នាក់ជាថ្នូរទៅនឹងអ្វីមួយដែលមានតម្លៃរួមមានសេវាកម្ម និង មនុស្ស ។

២. អំពើជួញដូរមនុស្សក្នុងនាមអ្នករត់ការ នឹងត្រូវផ្តន្ទាទោសដូចគ្នាអំពើជួញដូរមនុស្សដែរ។ ច្បាប់នេះក៏គូសបញ្ជាក់នូវទណ្ឌកម្មផងដែរចំពោះមនុស្សណាដែលពាក់ព័ន្ធនៅក្នុងដំណើរការជួញដូរចាប់តាំងពីអ្នកជួញដូរ សំខាន់បំផុតរហូតដល់អ្នកដែលជួយនៅក្នុងអំពើនេះ (ដូចជាអ្នកដឹកជញ្ជូន ផ្តល់ទីសំចត នឹងលាក់បំពួនជនរងគ្រោះជាដើម) ។

សេចក្តីព្រាងច្បាប់ថ្មីនេះមិនទាន់ត្រូវបានឯកភាពដោយរាជរដ្ឋាភិបាល និង បញ្ជូនទៅរដ្ឋសភានៅឡើយទេ។ គេពិនិត្យឃើញថា វាមានលក្ខណស្របទៅនឹងសេចក្តីព្រាងច្បាប់ព្រហ្មទណ្ឌថ្មីនៅចុងឆ្នាំ ២០០៦ ហើយត្រូវកែប្រែសិនមុននឹងដាក់ជូនទៅរដ្ឋសភាពដើម្បីពិនិត្យ ។

## **ករណីជួញដូរមនុស្ស ដើម្បីគោលបំណងអាជីវកម្មផ្លូវភេទដែលបានរាយការណ៍**

ក្នុងឆ្នាំ២០០៦នេះ លីកាដូ បានទទួលបណ្តឹងករណីជួញដូរមនុស្ស ដើម្បីគោលបំណងអាជីវកម្មផ្លូវភេទពីស្ត្រី ៦ នាក់រួមទាំង ណារីផងដែរ ។

---

[៤៤] ច្បាប់ស្តីពីការបង្ក្រាបអំពើចាប់ជំរិតមនុស្ស ជួញដូរមនុស្ស និង អាជីវកម្មលើមនុស្ស -មាត្រា ១០

### ករណីជួញដូរមនុស្ស ដើម្បីគោលបំណងអាជីវកម្មផ្លូវភេទសរុបរាយការណ៍ដោយ លីកាដូ ឆ្នាំ ២០០០-២០០៦




វាក៏ដូចគ្នានឹងអំពើហិង្សាក្នុងគ្រួសារ និង រំលោភសេពសន្ថវៈដែរ អំពើជួញដូរមនុស្សទំនងជាមិនសូវមានសេចក្តីរាយការណ៍ទេ។ នៅពេលដែលជនរងគ្រោះស្ថិតនៅក្នុងរបររកស៊ីផ្លូវភេទហើយ កត្តាជាច្រើនដោយរួមទាំងភាពក្រីក្រ ភាពអាម៉ាស់ ការរើសអើងពីសំណាក់សង្គម និងកង្វះការងារធ្វើច្រើនតែទុកឱ្យពួកគេទាំងនោះបន្តនៅក្នុងនោះតទៅទៀត។ សម្រាប់ស្ត្រី វាជាការលំបាកណាស់ក្នុងការទទួលបាននូវសេវាកម្មនានា ដែលអាចជួយពួកគេ (ជាពិសេសប្រសិនបើពួកគេត្រូវបានឃុំទុកក្នុងពេស្យាចារដោយបង្ខំ ឬត្រូវបានជួញដូរទៅប្រទេសដទៃ) ព្រមទាំងពិបាកសម្រាប់អង្គការមិនមែនរដ្ឋាភិបាលក្នុងការឃ្លាំមើលអំពីស្ថានភាពរបស់ពួកគេ។ ការពាក់ព័ន្ធរបស់អាជ្ញាធរនៅក្នុងអំពើជួញដូរ និង ពេស្យាចារក៏ទំនងជារាំងដល់ជនរងគ្រោះក្នុងការប្តឹងបណ្តឹងព្រហ្មទណ្ឌចំពោះជនដែលបានជួញដូរពួកគេ ។

## ការឆ្លើយតបរបស់រាជរដ្ឋាភិបាលចំពោះអំពើជួញដូរមនុស្សដើម្បីគោលបំណងអាជីវកម្មផ្លូវភេទ[៤៥]

### *គោលនយោបាយ និង ផែនការរបស់រាជរដ្ឋាភិបាល*

ដូចដំណើររឿងបានលើកឡើងពីខាងដើមរួចមកនៅក្នុងរបាយការណ៍[៤៦] ក្រសួងកិច្ចការនារីបានធ្វើសេចក្តីព្រាងផែនការស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីភេទ ប៉ុន្តែ នៅមិនទាន់មានការឯកភាពពីរាជរដ្ឋាភិបាលនៅឡើយទេ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៦ - ២០១០ បានគូសបញ្ជាក់នូវយុទ្ធសាស្ត្រ និង សកម្មភាពមួយចំនួនដើម្បីកាត់បន្ថយអំពើជួញដូរមនុស្សនៅកម្ពុជា។ ឧទាហរណ៍ផែនការបាននិយាយថា រាជរដ្ឋាភិបាលនឹង "ប្រយុទ្ធប្រឆាំងបញ្ហាជួញដូរស្ត្រី និង ទំនៀមទំលាប់ប្រពៃណីមួយចំនួនដោយផ្ទាល់ដែលទ្រទ្រង់អសមភាពយេនឌ័រដោយស្ងៀមស្ងាត់នៅក្នុងចំណុចជាច្រើននៃសង្គមជីវិតគ្រួសារ"[៤៧] និង "ដោះស្រាយការផ្លាស់ប្តូរនយោបាយដូចជា ត្រូវអនុម័តច្បាប់ជួញដូរមនុស្ស"[៤៨]។ ប៉ុន្តែ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដូចជាមិនមានគោលនយោបាយណាមួយដើម្បីអនុវត្តសកម្មភាពទាំងនេះក្នុងការកាត់បន្ថយអំពើជួញដូរមនុស្ស ដើម្បីគោលបំណងអាជីវកម្មផ្លូវភេទនៅកម្ពុជាទេ ។

គោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា ៣ — គោលដៅចម្បង ៨ បានចែងថារាជរដ្ឋាភិបាលនឹងកាត់បន្ថយឱ្យបានជាអតិបរមានូវរាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី និង កុមារដោយការតាក់តែងច្បាប់ប្រឆាំងនឹងរាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី និង កុមារដោយអនុលោមទៅតាមតម្រូវការ និង បទដ្ឋានអន្តរជាតិត្រឹមឆ្នាំ២០០៥។ ដោយហេតុថា រយៈពេលជាងមួយឆ្នាំហើយចាប់តាំងពីកាលបរិច្ឆេទដែលគេរំពឹងទុកសម្រាប់ការអនុម័តសេចក្តីព្រាងច្បាប់ប្រឆាំងអំពើជួញដូរមនុស្សនោះនៅតែឱ្យយើងឃើញថា តើរាជរដ្ឋាភិបាលនឹងសម្រេចគោលដៅនេះបានដោយរបៀបណា។ បើគ្មានច្បាប់ត្រឹមត្រូវ(និងការអនុវតន៏ច្បាប់នោះត្រឹមត្រូវទេ) ជនរងគ្រោះជាច្រើនដូចជា ហេង ណារី ជាដើម នោះនឹងនៅតែបន្តរងគ្រោះ ហើយត្រូវគេចាត់ទុកដូចជាទំនិញសុទ្ធសាធ ។ ជាការលំបាកណាស់នឹងឃើញថាអំពើជួញដូរមនុស្សដើម្បីគោលបំណងអាជីវកម្មផ្លូវភេទ ត្រូវថយចុះយ៉ាងណា ឬ លុបបំបាត់ចោលទាំងស្រុងនោះ ប្រសិនបើរាជរដ្ឋាភិបាលមិនអនុម័តច្បាប់ឱ្យបានគ្រប់គ្រាន់ ដើម្បីការពារជនរងគ្រោះដោយអំពើជួញដូរ និង ដើម្បីទប់ស្កាត់អំពើជួញដូរកុំឱ្យកើតឡើងទេនោះ ។

---

[៤៥] ចំពោះព័តិមានបន្ថែមស្តីពីគោលនយោបាយរបស់រាជរដ្ឋាភិបាលបច្ចុប្បន្ន និង អតីតកាល សូមអានរបាយការណ៍ចាស់របស់លីកាដូ អំពើហិង្សាលើស្ត្រី (ខែមករា ឆ្នាំ២០០៦) ទំ. ១៤ ។

[៤៦] សូមអានផ្នែកអំពើហិង្សាក្នុងគ្រួសារ – គោលនយោបាយរាជរដ្ឋាភិបាល ។

[៤៧] Op Cit 11, P. 75.

[៤៨] Op Cit 11, P. 76

## *កិច្ចព្រមព្រៀងអង្គការមិនមែនរដ្ឋាភិបាល*

នៅថ្ងៃទី ៦ កុម្ភៈ ២០០៧ ស្ថានប័នរដ្ឋពាក់ព័ន្ធ[៤៩] និង អង្គការមិនមែនរដ្ឋាភិបាលជាច្រើន[៥០] ចូលរួមការគាំទ្រជនរងគ្រោះដោយអំពើជួញដូរ ដោយបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយស្តីពីមាគ៌ាដើម្បីអនុវត្ត និងសហប្រតិបត្តិការរវាងស្ថាប័នរដ្ឋពាក់ព័ន្ធ ជាមួយនឹងភ្នាក់ងារគាំទ្រជនរងគ្រោះក្នុងករណីអំពើជួញដូរមនុស្ស" ។ កិច្ចព្រមព្រៀងបានគូសបញ្ជាក់នូវមាគ៌ាដើម្បីអនុវត្ត និងសហប្រតិបត្តិការរាជរដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាលក្នុងករណីអំពើជួញដូរមនុស្សដូចជា នីតិវិធីរំដោះជនរងគ្រោះដោយអំពើជួញដូរ ជាមួយនឹងការគិតគូរបឋមគឺ សុវត្ថិភាព សុខមាលភាព និង សិទ្ធិរបស់ជនរងគ្រោះ កិច្ចការពារជនរងគ្រោះក្នុងដំណើរការផ្តន្ទាទោស ការណែនាំចំពោះភស្តុតាង បញ្ហារបាយការណ៍ និង សក្ខីកម្ម សេវាកម្ម លក្ខខ័ណ្ឌ និង បុគ្គលិកមណ្ឌល ព្រមទាំងការធ្វើសមាហរណកម្មជនរងគ្រោះ ។

កិច្ចព្រមព្រៀងនេះមានគោលបំណង ដើម្បីកែ លំអសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្តល់សេវាកម្មដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ រដ្ឋាភិបាល មានសេវាកម្មតិចតួចបំផុតសម្រាប់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ហើយអង្គការសង្គមស៊ីវិលកម្ពុជាបាននឹងកំពុងបំពេញការខ្វះចន្លោះនេះ ដោយផ្តល់នូវសេវាកម្មផ្សេងទៀត។




កិច្ចព្រមព្រៀងនេះរួមមានវិធានការមួយចំនួនស្តីពីការស្តារនីតិសម្បទារដល់ជនរងគ្រោះដោយអំពើជួញដូរ ប៉ុន្តែ វិធានការទាំងនេះភាគច្រើនពាក់ព័ន្ធជាមួយនឹងជនរងគ្រោះដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលតែប៉ុណ្ណោះ ពុំបានគ្របដណ្តប់ដល់តម្រូវការសេវាកម្មផ្សេងៗទេ ដូចជាការប្រឹក្សាយោបល់ជនរងគ្រោះនៅតាមផ្ទះជាដើម។ កិច្ចព្រមព្រៀងនេះ ក៏មានបញ្ចូលវិធានការមួយចំនួនស្តីពីការធ្វើសមាហរណកម្មជនរងគ្រោះ ប៉ុន្តែជាថ្មីម្តងទៀត វិធានការទាំងនេះពាក់ព័ន្ធជាសំខាន់តែជាមួយការធ្វើសហមារណកម្មជនរងគ្រោះ ដោយអំពើជួញដូរដែលស្នាក់នៅក្នុងមណ្ឌល

---

[៤៩] ក្រសួងយុត្តិធមិ ក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទារ និង ក្រសួងសុខាភិបាល ។

[៥០] មជ្ឈមណ្ឌលកម្ពុជាដើម្បីស្ត្រីមានវិបត្តិ កុមាររីករាយ វឌ្ឍនះភាព ការពារយុត្តិធមិកុមារ មជ្ឈមណ្ឌលសុខភាព សម្រាប់កុមារ អភិវឌ្ឍន៍ស្ត្រីកម្ពុជា សមាគមកុមារកម្ពុជាប្រឆាំងនឹងគ្រោះអត់ឃ្លាន អំពើហិង្សា ជំនួយកុមារដើម្បី ការចូលរួម និង ប្រមូលផ្តុំ គាំទ្រផ្នែកច្បាប់សម្រាប់កុមារ និង ស្ត្រី ពន្លឺកុមារកម្ពុជា សមាគមន៏គាំទ្រកុមារកម្ពុជាថ្មី មូលនិធិប៉ុប៉ាង អង្គការដំណក់ទឹក មជ្ឈមណ្ឌលគ្រួសារតាមចិញ្ចើមផ្លូវ សមាគមកុមារ និង សេចក្តីស្រឡាញ់កម្ពុជា (AIDe TouS,) មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (ECPAT)អង្គការសេចក្តីសង្ឃឹមកម្ពុជា ជំនួយផ្នែកច្បាប់កម្ពុជា កុមារនៃក្តីសង្ឃឹម កុមារគ្មានព្រំដែន អនាគតកុមារ និងមជ្ឈមណ្ឌលឆ្លងកាត់ប៉ោយប៉ែត ។

បច្ចុប្បន្នប៉ុណ្ណោះ។ កិច្ចព្រមព្រៀងក៏ពុំបានពិភាក្សាវិធានការឱ្យបានជាក់លាក់ ដើម្បីធ្វើសមាហរណកម្មជនរងគ្រោះដែលត្រូវជួញដូរជាអន្តរជាតិទេ។ ដោយកិច្ចព្រមព្រៀងនេះជាជំហ៊ានមួយនៅក្នុងទិសដៅដ៏ត្រឹមត្រូវជាពិសេសចំពោះការផ្តល់ការគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នោះវានឹងត្រូវចំណាយពេលវេលាច្រើន ដើម្បីវាយតម្លៃនូវផលចំណេញ និង ភាពឆាប់រហ័សនៃកិច្ចព្រមព្រៀងនេះ។

## *ពិធីសារអង្គការសហប្រជាជាតិស្តីពីអំពើជួញដូរមនុស្ស*

រាជរដ្ឋាភិបាលកម្ពុជាក៏បានផ្តល់សច្ចាប័នលើពិធីសារបន្ថែមរបស់អង្គការសហប្រជាជាតិ ដើម្បីទប់ស្កាត់បង្ក្រាប និង ដាក់ទណ្ឌកម្មអំពើជួញដូរមនុស្ស ជាពិសេស ស្ត្រី និង កុមារ កាលពីថ្ងៃទី ១៦ មករា ឆ្នាំ ២០០៦ កន្លងទៅនេះ។ ពិធីសារជួញដូរនេះ មានគោលបំណងសំខាន់ៗ ៣ គឺ ទប់ស្កាត់ និង ប្រយុទ្ធប្រឆាំង នឹងអំពើជួញដូរមនុស្ស ដោយយកចិត្តទុកដាក់ជាពិសេសទៅលើស្ត្រី និង កុមារ - ការពារនឹងជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយគោរពសិទ្ធិទាំងស្រុងរបស់ជនរងគ្រោះ និង លើកស្ទួយកិច្ចសហប្រតិបត្តិការក្នុងចំណោមរដ្ឋនានា ដើម្បីសម្រេចគោលបំណងនេះឱ្យបាន។ ពិធីសារនេះបានលើកឡើងជាច្រើននូវវិធានការ ដើម្បីការពារជនរងគ្រោះរួមទាំងវិធានការ ដើម្បីទប់ស្កាត់កុំឱ្យទទួលរងគ្រោះជាលើក២។

□□□

# ៥. សេចក្តីសន្និដ្ឋាន និង អនុសាសន៍

ស្រី មុំ លី វីដែន ដេត និង ហេង ណារី ជាជនរងគ្រោះយ៉ាងធ្ងន់ធ្ងរក្រោមការប្រព្រឹត្តិហិង្សាពីជនល្មើសដោយឡែក១ពីគ្នា។ នៅក្នុងករណីរបស់ពួកគេទាំងអស់ គ្មានហេតុផលណាមួយដែលពួកគេត្រូវទទួលរងការប្រព្រឹត្តិអំពើសាហាវព្រៃផ្សៃ និងហិង្សាចំពោះគេឡើយ ឬក៏ដោយសារកត្តាណាផ្សេងទៀតឡើយ - គឺពួកគេទាំងអស់ជាស្ត្រីរស់នៅក្នុងប្រទេសកម្ពុជា។ មិនថាអំពើហិង្សាធ្លាក់មកលើរាងកាយ ផ្លូវចិត្ត ឬ ផ្លូវភេទទេ ស្ត្រីទាំងនេះរួមទាំងស្ត្រីជាច្រើនទៀតស្ថិតក្នុងភាពស្ងៀមស្ងាត់ ស្ត្រីដែលមិនបញ្ចេញឈ្មោះ លាក់មុខមាត់ទាំងឡាយ គឺជាជនរងគ្រោះនៃអំពើរំលោភដោយហិង្សាបំផុតនៅកម្ពុជា - នោះគឺអំពើហិង្សាលើស្ត្រី ។

បញ្ហាហិង្សាធ្ងន់ធ្ងរលើស្ត្រីនៅកម្ពុជានឹងមិនអាចកែលំអបានទេ ប្រសិនបើរាជរដ្ឋាភិបាលពុំមានឆន្ទៈក្នុងការអនុវត្តនីតិវិធានការតឹងរឹង ដើម្បីប្រយុទ្ធប្រឆាំងវាទេនោះ។ នៅពេលដែលមានឆន្ទៈនយោបាយតិចតួច ឬ គ្មានត្រូវបានបង្ហាញដើម្បីជួយក្រុមដែលងាយរងគ្រោះបំផុតនៅក្នុងសង្គមកម្ពុជា ស្ថានភាពនឹងនៅដដែល ជាមួយនឹងស្ត្រីកម្ពុជារាប់មិនអស់ត្រូវរងនូវអំពើរំលោភយ៉ាងហិង្សា។ រាជរដ្ឋាភិបាលបានខកខានក្នុងការសម្រេចនូវកាតព្វកិច្ចក្រោមច្បាប់ CEDAW ហើយបានទុកឱ្យហួសកាលវិច្ឆេទសំខាន់ៗក្នុងការអនុម័តច្បាប់ និង អនុវត្តគោលនយោបាយអប់រំក្រោមគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា ។

លីកាដូទាមទារឱ្យសហគមន៍អន្តរជាតិ និង សង្គមស៊ីវិលនៅកម្ពុជាបន្តមានឥទ្ធិពលលើរាជរដ្ឋាបាលកម្ពុជាដើម្បីធ្វើការតាក់តែង និងការអនុវត្តច្បាប់ គោលនយោបាយ និង វិធានការនានាដែលសំដៅដោះស្រាយបញ្ហានេះឱ្យមានប្រសិទ្ធិភាព ហើយអប់រំប្រជាពលរដ្ឋកម្ពុជាអំពីការប្រកាន់ខ្ជាប់នូវសិទ្ធិរបស់ស្ត្រី និង ភាពខុសច្បាប់ និងភាពសាហាវនៃហិង្សាដែលធ្លាប់មានកន្លងមក។

## អនុសាសន៍

១. សហគមន៍អន្តរជាតិគួរប្រើប្រាស់នូវឥទ្ធិពលរួមរបស់ខ្លួន ដើម្បីធានាឱ្យរាជរដ្ឋាភិបាលកម្ពុជាសម្រេចឱ្យបាននូវកាតព្វកិច្ចរបស់ខ្លួនតាមអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី និងគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា។

២. សង្គមស៊ីវិលគួរធ្វើការយ៉ាងស្អិតរមួត ដើម្បីនាំមកនូវការយកចិត្តទុកដាក់ដល់បញ្ហាបន្ទាន់ៗជាទីបំផុតទាក់ទងនឹងហិង្សាលើស្ត្រី និង ប្រើប្រាស់ឱកាសនានា ដើម្បីទទូចសុំរាជរដ្ឋាភិបាលកម្ពុជាសម្រេចឱ្យបាននូវ

កាតព្វកិច្ចរបស់ខ្លួនក្រោមអនុសញ្ញាស្តីពីការលុបបំបាត់នូវរាល់ទម្រង់នៃអំពើរើសអើងប្រឆាំងនឹងស្ត្រី និង គោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា។ ជាពិសេស លីកាដូ ទាមទារឱ្យសហគមន៍អន្តរជាតិ និង សង្គមស៊ីវិលឱ្យបញ្ចុះបញ្ចូល និង ជំរុញសុំរាជរដ្ឋាភិបាលកម្ពុជាឱ្យអនុវត្តអនុសាសន៍ខាងក្រោមជាបន្ទាន់។[៥១]

- អនុម័តច្បាប់ទាំងអស់ដែលទាក់ទងទៅនឹងហិង្សាលើស្ត្រីដោយអនុលោមតាម (CEDAW) និងឧបករណ៍អន្តរជាតិផ្សេងទៀត។ ជាពិសេស ត្រូវអនុម័តសេចក្តីព្រាងច្បាប់ស្តីពីអំពើជួញដូរមនុស្ស និង អាជីវកម្មផ្លូវភេទ និង អនុវត្តមាត្រាមួយចំនួនឱ្យបានសមស្រប ។
- អនុម័តច្បាប់ស្តីពីអំពើរំលោភសេពសន្ថវៈដែលបំភ្លឺនូវនិយមន័យនៃពាក្យ "យល់ព្រម" ព្រមទាំងធាតុខ្លះៗនៃបទល្មើស (ឧ. ការបំពារបំពាន ឬ ការឈ្លានពានណាមួយនឹងត្រូវចាត់ទុកជាអំពើរំលោភសេពសន្ថវៈ)។
- អនុវត្តអនុក្រិត្យសម្រាប់ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង ការពារជនរងគ្រោះ ដែលចាត់ចំណាត់ថ្នាក់ការប្រតិបត្តិការច្បាប់ ។
- ចុះធ្វើយុទ្ធនាការអប់រំ និង លើកកំពស់ការយល់ដឹងនៅទូទាំងប្រទេសដោយផ្តោតទៅលើនគរបាល មេធាវី ចៅក្រម និង ជាពិសេសសាធារណជនទូទៅស្តីពីអំពើហិង្សាក្នុងគ្រួសារ រំលោភសេពសន្ថវៈ និង អំពើជួញដូរមនុស្សដើម្បីគោលបំណងអាជីវកម្មផ្លូវភេទ និង ច្បាប់ពាក់ព័ន្ធមួយចំនួន និង ដំណើរការនានា។ ជាពិសេសការសង្កត់ធ្ងន់ត្រូវផ្តោតទៅលើបុរសកម្ពុជា និង អ្នករស់នៅតាមតំបន់ជនបទ។
- ផ្តល់ការហ្វឹកហ្វឺនដល់នគរបាល មេធាវី និង តុលាការដែលជាការទទួលស្គាល់ និង ប្រយុទ្ធប្រឆាំង នឹងអំពើហិង្សាក្នុងគ្រួសារ រំលោភសេពសន្ថវៈ និង អំពើជួញដូរមនុស្សដើម្បីគោលបំណងអាជីវកម្មផ្លូវភេទនៅកម្ពុជា ។
- បើកយុទ្ធនាការអប់រំ ជាពិសេសនៅតាមតំបន់ជនបទ ដើម្បីប្រយុទ្ធប្រឆាំងនឹងគំនិតប្រពៃណីចាស់ដែលយល់ថា ស្ត្រីគឺជាភេទទន់ខ្សោយជាងបុរស និងដើម្បីជម្រាបដល់ស្ត្រីទាំងឡាយអំពីសិទ្ធិរបស់ខ្លួន។
- បង្កើនចំនួនមន្ត្រីអនុវត្តច្បាប់ និង មន្ត្រីផ្នែកច្បាប់ជាស្ត្រីដែលមានការហ្វឹកហ្វឺនបានល្អ ដើម្បីធ្វើការជាមួយបញ្ហាអំពើហិង្សាក្នុងគ្រួសារ រំលោភសេពសន្ថវៈ និង ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។
- ផ្តល់សេវាកម្មពិគ្រោះយោបល់ និង និតិសម្បទារដល់ជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈ ហិង្សាក្នុងគ្រួសារ និង ជួញដូរមនុស្ស។
- ផ្តល់សេវាកម្មសមាហរណកម្ម និង មាតុភូមិនិវត្តន៍ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ហើយជួយអង្គការមួយចំនួនដែលបានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចខិតខំប្រឹងប្រែងនានា។

[៥១] អនុសាសន៍ភាគច្រើនត្រូវបានផ្សព្វផ្សាយរួចហើយនៅក្នុងរបាយការណ៍លីកាដូកាលពីមុន ប៉ុន្តែនៅមិនទាន់បានអនុវត្ត ដោយរាជរដ្ឋាភិបាលនៅឡើយទេ ។

- អប់រំមន្ត្រីច្បាប់ និង តុលាការអំពីការបកស្រាយច្បាប់ អំពើហិង្សាក្នុងគ្រួសារ រំលោភសេពសន្ថវៈ និង ជួញដូរមនុស្ស។ ផ្តន្ទាទោសមន្ត្រីណាដែលបកស្រាយច្បាប់ខុស និង រំលោភច្បាប់ រួមទាំងអ្នកដែលចូលរួមនៅក្នុង ឬ សម្របសម្រួលឱ្យមានការសងសំណងរដ្ឋប្បវេណី ឬទទួលសំណូកពីជនល្មើស ។
- វាយតម្លៃនូវប្រសិទ្ធិភាពរបស់វិធានការរាជរដ្ឋាភិបាល និង កម្មវិធីកាត់បន្ថយអំពើជួញដូរលើស្ត្រី។
- ផ្តល់ការហ្វឹកហ្វឺន និង អប់រំដល់នគរបាល និងមន្ត្រីតាមព្រំដែនដែលធ្វើការជិតដិតនឹងអំពើជួញដូរ និង មណ្ឌលពាណិជ្ជកម្មផ្លូវភេទ ។

□□□